Free

សារព័ត៌មាន ខ្មែរផុស ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉ឺមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្តូរសេវាកម្ម • ការវេចខ្ចប់ឱសថ • ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ • ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្តូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

# ឡូវែលទទួលឧត្តមសេនីយ ហ៊ុន ម៉ាណែត



លោក ហ៊ុន ម៉ាណែត នៅឡូវែល




បាតុកម្មសហគមន៍ខ្មែរឡូវែលប្រឆាំងវត្តមានលោក ហ៊ុន ម៉ាណែត

**ខ្មែរផុសស.រ.អា.**

**ឡូវែលរដ្ឋម៉ាសាឈូសិត:** ប្រជាពលរដ្ឋខ្មែរឡូវែលប្រមាន៣០០នាក់ បានត្រៀមខ្លួនមកទទួលឧត្តមសេនីយ ហ៊ុន ម៉ាណែត នាយអគ្គសេនាធិការងនៃកងខេមរភូមិន្ទនឹងជាកូនប្រុសរបស់លោកនាយករដ្ឋមន្ត្រីយូរឆ្នាំ ហ៊ុន សែន កាលពីថ្ងៃទី១៧ មេសាកន្លងទៅតែពុំមែនក្នុងភាពរីករាយទេ គឺក្នុងបរិយាកាសពោរពេញដោយកំហឹងសម្តែងឆន្ទៈមិនចង់ឃើញមេទ័ពរូបនេះមកបង្ហាញខ្លួននៅទីក្រុងឡូវែលដ៏សម្បូរខ្មែរអតីតជនភៀសខ្លួនរស់នៅនោះទេ។ ក្រុមហ្វូងបាតុករឈរនៅម្ខាងថ្នល់នាឧទ្យាន"ក្លេម៉ង់តេផាក"រារាំងដោយក្រុមប៉ូលីសយ៉ាងច្រើននឹងក្រុមអង្គរក្សដ៏ច្រើនរបស់លោក ហ៊ុន ម៉ាណែត ដែលឈរនៅម្ខាងទៀតនៅពីមុខភោជនីយដ្ឋាន"ប៉ៃលិន" ដើម្បីការពារសន្តិសុខឧត្តមសេនីយចៅហ្វាយនាយដែលមកធ្វើពិធីជប់លៀងភោជនាហារនៅហាង "ប៉ៃលិន" ជាន់ទី២នោះ។

ក្រុមបាតុករបានមករង់ចាំការមកដល់របស់ហ៊ុន ម៉ាណែត តាំងពីម៉ោង៥ល្ងាចនៃថ្ងៃអាទិត្យទី១៧ តែរហូតដល់ម៉ោង៩យប់ ទើបគេដឹងថាបានលបចូលភោជនីយដ្ឋាន "ប៉ៃលិន" យ៉ាងសម្ងាត់តាមទ្វារក្រោយរួចទៅហើយ។ បាតុករនៅខាងក្រៅឯណោះបានស្រែកតាមឧគ្ឃោសនស័ព្ទយ៉ាងអឺងកង ដូចជាពាក្យ "ហ៊ុន ម៉ាណែត ត្រឡប់ទៅផ្ទះវិញទៅ!" ឬក៏បញ្ជូនសារថា "ហ៊ុន សែន ក្បត់ជាតិលក់ដីឱ្យយួន!" ឬក៏ស្រែកថា "ដោះលែង ហុង ស៊ុនហួត- មាច សុវណ្ណរា- អ៊ុំ សំអាន"ឬក៏ស្រែកថា"ឱ្យដោះលែងសកម្មជនដីធ្លី!" ឬក៏មានថា "ហ៊ុន ម៉ាណែតក្បត់ជាតិ!"... គ្មាននរណាក្រៅពីមនុស្សជិតស្និតខាងគណបក្សប្រជាជនអាចចូលរួមបានទេ ហើយក៏ទំនងជាគ្មានអនុញ្ញាតឱ្យថតរូបបង្ហោះតាម"ហ្វេសប៊ុក"ចេញជូនជាពត៌មានបាន ដូចពេលមុនៗនោះទេ។ លោក ខឹម ចន្ថា ដែលគេឃើញមានម៉ាស៊ីនថតវិដេអូកាន់នៅដៃចូលទៅរួមពិធីជប់លៀងដែរនោះ **តទៅទំព័រទី ០៣**

## វិចារណកថា

# នៅឡូវែលខ្មែរអាមេរិកាំងធ្វើ"អភិវឌ្ឍន៍"ឬ"បដិវត្ត"



ពិន សំខុន

**ដោយ ពិន សំខុន**

●●●ខ្មែរអាមេរិកាំងច្រើនរយនាក់នៅឡូវែលបានចេញមកសម្តែងមតិនៅឱកាសសម័យប្រជុំសមាជិកគណក្រុមប្រឹក្សាក្រុង កាលពីថ្ងៃទី៥មេសា២០១៦កន្លងទៅ បណ្តាលឱ្យសាលាក្រុងឡូវែលប្តូរសេចក្តីសម្រេចចិត្តដ៏សំខាន់មួយ"បដិសេធមិនទទួលភ្ញៀវកិត្តិយសរបស់ខ្លួនមកពីកម្ពុជា តាមសំណើរមតិភាគច្រើននៃសហគមន៍ខ្មែរ"។

ក្រោយពីព្រឹត្តិការណ៍នៅសាលាក្រុងមួយសប្តាហ៍ក្នុងកិច្ចពិភក្សាសហគមន៍មួយដោយការណាត់គ្នាដែលរួមប្រជុំដោយមានដំណាងប្រមាណ៣០នាក់បានតាំងសំនួរមួយថា"តើសកម្មភាពសហគមន៍ខ្មែរនៅសាលាក្រុងកាលពីថ្ងៃទី៥នោះរាប់បានថា ជាជោគជ័យដែរឬក៏អត់?"។

ព្រឹត្តិការណ៍នោះ គឺជាសកម្មភាពរួមដំបូងបង្អស់ដែលក្រុមមនុស្សគ្មានសម្លេងរាប់រយនៅឡូវែលដែលធ្លាប់តែទុកដាក់វាសនាខ្លួនឱ្យទៅអ្នកដទៃជាអ្នកដោះស្រាយឱ្យត្រឡប់មកបញ្ចេញស្នាដៃបង្ហាញមតិដោយខ្លួនឯងវិញ ។ លទ្ធផលទទួលបាន១០០% ទប់ស្កាត់ដំណើរដែលក្រុមមនុស្សប្រមានជាង១០នាក់ ចាត់ទុកថា **តទៅទំព័រទី ២៥**

The 6th Annual
ខ្មែរផុស KhmerPost USA
Media & Community Gala
Present Partners GREATER LOWELL CHAMBER OF COMMERCE UMASS LOWELL
APA Heritage Month Celebration
Friday, May 20, 2016
5:30p.m -10p.m
Sompao Meas Hall
450 Chelmsford St. Lowell, Massachusetts
Tickets info, please contact: Soben Pin 978-656-8141 or visit: www.khmerpost.us/gala-2016

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី :
យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!



▸ ផ្តល់សេវាដល់ទីលំនៅ
▸ ខ្ចប់ឱសថតាមបំណង
▸ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

# ហ៊ីឡារី គ្លីនតុន នឹង ឌណាល ត្រម ឈ្នះ"ស៊ូពើរធូស្ដេ"ថ្មីម្ដងទៀត

## Hilary Clinton and Donald trumph win another super Tuesday

**ដោយ ខ្មែរផុសស.រ.អា.**

ហ៊ីឡារី គ្លីងតុន ខាងគណបក្សប្រជាធិបតេយ្យបានទទួលជ័យជំនះយ៉ាងត្រចះត្រចង់លើ បេនី សេនឌឺ នៅក្នុងភូមិកំណើតនៅក្រុង"ញូយ៉ក" របស់គាត់ -ការប្រឹងខិតខំដោយសម្រេចបានលទ្ធផល៥៧.៩%ទល់នឹង ៤២.១% នា "ស៊ូព័រធូស្ដេ" ថ្ងៃទី១៩មេសានេះ -លទ្ធផលនេះបានជម្រុញចំនួន"ដេលេគ្គេត"របស់ ហ៊ីឡារី បានឡើងទៅជា ១៩៣០ទល់នឹងចំនួន"ដេលេគ្គេត"របស់ ដានី ឡើងបាន១២២៣"ដេលេគ្គត"។







ដើម្បីឱ្យបានទទួលការតែងតាំងនៅមហាសន្និបាតបានបេក្ខជនខាគណបក្សប្រជាធិបតេយ្យត្រូវធានា"ដេលេគ្គេត"ចំនួន២៣៨៣នាក់។

រីឯ ឌណាល ត្រម ខាងគណបក្សសាធារណរដ្ឋវិញ បានឈ្នះដាច់លើ ខេស៊ីក នឹង ថេត គ្រូស រួមគ្នាដោយបានទទួលលទ្ធផល. ត្រម ៦០.៤%, ខេស៊ីក ២៥.១%, គ្រូស ១៤.៥% ។ចំនួន "ដេលេគ្គេត" បានឡើងរៀងៗខ្លួនទៅជា ត្រម ៨៤៧ គ្រូស ៥៥៣ (ឥតប្រែប្រួលពីព្រោះឥតបានដេលេគ្គេតថ្មីទេ) ខេស៊ិក១៤៨។

ខាងគណបក្សសាធារណរដ្ឋត្រូវទទួលបានដេលេគ្គេតចំនួន១២៧៣ ទើបអាចទទួលការតែងតាំងបាន។

បើគិតលេខតាមចំនួនរដ្ឋដែលនៅសល់ហើយត្រូវបែងយកដេលេគ្គេតឱ្យបានទៅពេលខាងមុខ គ្រូស នឹង ខេស៊ីក មិនអាចរកដេលេគ្គេតឱ្យបានគ្រប់ចំនួន,សម្រាប់ការតែងតាំងជាបេក្ខជនប្រធានាធិបតីបានទៀតទេ...ក៏ប៉ុន្តែបេក្ខជនបឋមទាំង២នាក់ចុងក្រោយនេះ នៅឈរឱ្យគេបោះឆ្នោតឱ្យនៅឡើយ ពីព្រោះពួកគាត់ចង់នៅរំខានបេក្ខភាព ឌណាល ត្រម ដោយតាមធ្វើមិនឱ្យ ត្រម ឡើងដល់គ្រប់ចំនួន១២៧៣ បាន. ពេលនោះនឹងមានការជ្រើសរើសសារជាថ្មីនៅមហាសន្និបាតគណបក្ស...នៅពេលនោះហើយដែល ថេត គ្រូស នឹង ខេស៊ីក នៅមានសង្ឃឹមបន្តិចទៀតនៅឡើយថា សមាជិកបក្សអាចនឹងជ្រើសរើសខ្លួនឡើងមកវិញបាន។





អ្នកវិភាគជាច្រើនមើលឃើញថា នៅបន្តទៅមុខទៀតនោះ ហ៊ីឡារី ហើយនឹង ត្រម អាចនឹងមានសំណាងឈ្នះ នៅហ្វីឡាដែលហ្វៀ កូណិចទីកិត រ៉ូដអាយឡិន ដែលវែ នឹង មែរីឡែនទៀតនៅឡើយ។ ហ៊ីឡារី មុខជានឹងបានការតែងតាំង រីឯ ត្រម ក៏ទំនងជាមិនមានការជ្រើសរើស, ក្រៅពីលទ្ធផលនៃការបោះឆ្នោតនោះទេ៕

# ប្រវត្តិបុណ្យចូលឆ្នាំខ្មែរ

**ដោយ ពិន សំខុន**

ពិធីបុណ្យចូលឆ្នាំខ្មែរ គឺជាបុណ្យប្រចាំឆ្នាំដ៏ធំជាងគេបង្អស់សម្រាប់បងប្អូនខ្មែរយើង។ រៀងរាល់ឆ្នាំពិធីនេះ បានត្រូវរៀបចំដោយរដ្ឋអំណាចដោយគ្រួសារនឹងដោយបុគ្គលម្នាក់ៗ ដូច្នេះមានសារៈសំខាន់មិនអាចខកខានបានឡើយ។

នៅសហរដ្ឋអាមេរិកនេះវប្បធម៌ខ្មែរមួយនេះ មិនមានបាត់បង់ទេ ថ្វីត្បិតតែនៅឆ្ងាយពីមាតុប្រទេសឆ្ងាយពីញាតិសណ្ដានក៏ដោយ។ នៅឡូវែលនេះ ក៏ដូចជានៅតំបន់ឯទៀតនៃសហរដ្ឋដែលមានខ្មែររស់នៅគេនាំគ្នារៀបតុប្រកបដោយផ្កាភ្ញីនំចំណី ហើយអុចធូបទទួលទេវតាថ្មី... បន្ទាប់មកគេទៅធ្វើបុណ្យប្រគេនចង្ហាន់ព្រះសង្ឃនឹងពូនភ្នំខ្សាច់ក្នុងវត្តអារាមមានស្រង់ព្រះ, ពេលខ្លះទៀតក្មេងៗនាំគ្នាលេងបោះអង្គុញលោតអន្ទាក់លាក់កន្សែងទាញព្រ័ត្រ រាំវង់...។ល។ ហើយពិធីចូលឆ្នាំ ក៏ជាឱកាសដ៏កំរដែលមាតាបីតាអនុញ្ញាតិឱ្យកូនស្រីក្រមុំរបស់ខ្លួនចេញមកលេងល្បែងកំសាន្តជាមួយកម្លោះៗបាន, រឹតតែញ៉ាំងឱ្យពិធីបុណ្យចូលឆ្នាំរឹតតែមានន័យសម្រាប់ក្រុមយុវជននឹងយុវនារីជាទីបំផុត។

ប្រវត្តិវិទូខ្មែរ"មីសែលត្រាណេ"បានរកឃើញថា ប្រទេសខ្មែរកាន់ព្រះពុទ្ធសាសនានៅ២ជំនាន់ធំៗ គឺ១-នៅមុនគ្រឹស្តសករាជ្យដែលគេហៅថា "បុរេប្រវត្តិសាស្ត្រ" ដែលព្រះពុទ្ធសាសនាមានឥទ្ធិពលគ្របដណ្ដប់លើដីគោគពីឥណ្ឌាមកដល់


វត្តពន្លឺពុទ្ធិចក្រថ្ងៃចូលឆ្នាំ

ភូមា-ខ្មែរ-នឹងចិន។ ពីសតវត្សទី១រហូតដល់សតវត្សទី១០ប្រទេសខ្មែរដោយមានវង្សព្រះ-មហាក្សត្រមកពីវប្បធម៌ឥណ្ឌាបានប្រកាន់យក "ពហុទេវក្នុងព្រហ្មញ្ញសាសនា"ជាសាសនារបស់រដ្ឋនឹងទី២-ជំនាន់ព្រះពុទ្ធសាសនាមួយទៀតប្រកាន់ដោយព្រះបាទជ័យវរម្ម័នទី៧ ដែលបានប្រកាន់យកសាសនា"ព្រះពុទ្ធមហាយាន-និកាយពេជ្រយាន"តែមួយអង្គឯងគត់ក្នុងចំណោមព្រះមហាក្សត្រដែលគ្រប់គ្រងកម្ពុជាក្នុងប្រមាណ១៥សតវត្សនៃដើមគ្រឹស្តសករាជ្ជ។ គឺនៅជំនាន់នេះ ហើយដែលប្រវត្តិប្រទេសកម្ពុជាមានស្នាមប្រកួតប្រជែងយ៉ាងខ្លាំងខ្លាជាមួយនឹង"ទ្រឹស្តីសាសនាព្រាហ្ម" មានជំនឿលើអារក្ស អ្នកតា ប្រើមន្តអាគមមានឫទ្ធានុភាពដែលបណ្ដាលឱ្យពលរដ្ឋប្រារព្ធពិធីបុណ្យចូលឆ្នាំពាក់កណ្ដាលជាសាសនាព្រះពុទ្ធ,



នឹងពាក់កណ្ដាលទៀតជាព្រហ្មញ្ញសាសនា ឬក៏សាសនាមហាយានយ៉ាងហោចណាស់ ក៏ចាប់តាំងពីពេលនោះឯងមកដែរ។

លោក"មីសែលត្រាណេ"បានសរសេរថា ព្រះបាទជ័យវរម្ម័នទី៧ មានឈ្មោះមួយទៀតថា "ធនជ័យ"ដែលធ្វើឱ្យគេនឹកទៅដល់រឿងនិទានដែលគ្មានឈ្មោះអ្នកនិពន្ធនៅក្នុងនោះកុមារនឹងបុរស "ធនជ័យ"មានប្រាជ្ញាឆ្លាតវាងវៃរហូតបានក្លាយជាវីរៈបុរសជាតិនឹងអន្តរជាតិដោយសារចំនេះលើព្រះពុទ្ធសាសនាក្នុងចក្រវាឡជំនួសមុខឱ្យព្រះរាជារបស់ខ្លួន។ នៅមាន "រឿងរាមកេរ" ខ្មែរដែលគេយល់ថា បានបកប្រែចេញពីគម្ពីរឥណ្ឌា "រ៉ាមាយ៉ានៈ"តែតាមពិតបានបញ្ចុះតម្លៃតួអង្គព្រះរាមឱ្យទាបជាងអវតាររបស់ព្រះពុទ្ធថាទន់ជ្រាយគ្មានកម្លាំង បើកុំតែមានព្រះលក្សជាអាណុជនឹងហនុមានពុំអាចឈ្នះក្រុងរាពបានទេ ផ្ទុយស្រឡះពីរឿងដើម"រ៉ាមាយ៉ានៈ"ដែលព្រះរាមជាតួអង្គទេវៈព្រះព្រហ្ម **តទៅទំព័រទី ០៤**

## តមកពីទំព័រទី ០១ ឡូវែលទទួលឧត្តមសេនីយ ហ៊ុន ម៉ាណែត

ក៏មិនឃើញបញ្ចេញរូបភាពឱ្យគេបានឃើញផងទេ។ តូនី ពេជ្រ បានត្រូវគេជូលឱ្យថតរូបដើម្បីឱ្យផ្សព្វផ្សាយតែម្នាក់គត់។

មុននេះមួយថ្ងៃ លោកហ៊ុន ម៉ាណែត អមដោយលោករដ្ឋមន្ត្រីក្រសួងការបរទេសថ្មី ប្រាក់ សុខុន នឹងលោក ផលរដ្ឋា យ៉ែម បានទៅផ្តល់បទសម្ភាសន៍១ម៉ោង ជាមួយសារព័ត៌មានក្នុងតំបន់ "ឡូសាន់" ដឹកនាំដោយនាយក ជីម ខាំប៉ាលីនី សាធារណជនក៏បានទទួលសេចក្តីបំភ្លឺមួយចំនួនធំពីមន្ត្រីសំខាន់មកពីកម្ពុជាម្នាក់នេះ តាមរយៈឱ្យរដ្ឋអំណាចឃាត់ខ្លួនបាន... ម៉ាណែត មានថែមទាំងលើកឡើងថា ធ្លាប់បានឃើញប៉ូលីសអាមេរិកាំងដាក់ខ្នោះ សមាជិកព្រឹទ្ធសភាដែលគេបង្គាប់ឱ្យចាកចេញពីផ្លូវមួយ ហើយមិនព្រមចេញ។ ម៉ាណែត បានសម្តែងការភ្ញាក់ផ្អើលនៅពេលសាលាក្រុងមិនបានទទួលខ្លួនជាផ្លូវការ ជាពិសេសមិនទទួលយករូបចម្លាក់ជ័យវរ្ម័នទី៧ដែលថា លោកអតីតអភិបាលក្រុង រ៉តនី អេលីយ៉ុត បានស្នើសុំ... នៅលើប្រយោគនេះបានធ្វើឱ្យ រ៉តនី អេលីយ៉ុត ច្រឡោតហើយក៏ចេញសេចក្តីថ្លែង


សម្ភាសន៍ ហ៊ុន ម៉ាណែត ជាមួយឡូសាន់





រូបភាពបង្ហោះដោយ"វីដេអូរបស់ឡូសាន់"។

តាមរយៈបទសម្ភាសនិនោះ គេដឹងថា ឧត្តមសេនីយ ហ៊ុន ម៉ាណែត បានទទួលដំណឹងតិចតួចពីសហគមន៍ដែលកំពុងខឹងសម្បារនឹងលោក. ព្រមទាំងឪពុករបស់លោកជានាយករដ្ឋមន្ត្រីដ៏យូរអង្វែងនៅប្រទេសកម្ពុជា ដូចជាថា "លោកមិនដឹងថា បាតុករនៃសហគមន៍ខ្មែរ នៅឡូងបិច

ការតបវិញភ្លាមថា "ជាការមិនពិត! លោកមិនដែលបានសុំរូបចម្លាក់នោះ ទោះជាដោយលិខិតក្តី ឬក៏ដោយផ្ទាល់មាត់ក្តីម្តងណាទេ!" ហើយទាមទារឱ្យ ហ៊ុន ម៉ាណែត ផ្តល់នូវភស្តុតាងដែលថា លោកបានស្នើសុំរូបចម្លាក់នោះផង។

កូនលោក ហ៊ុន សែន ចេញមកបំពេញទស្សនៈកិច្ចនាឱកាសចូលឆ្នាំថ្មីឆ្នាំវក ព.ស.២៥៦០




រ៉ូដនី អ៊ីលៀត

ក៏ដូចនៅឡូវែល មិនដឹងជាចង់បានអ្វីច្បាស់លាស់ទេ?" ម្យ៉ាងទៀតនៅពេល ជីម សួរថា លោកដឹងហើយថា នៅអាមេរិកនេះ គេអាចនិយាយ "ត្រូវ" ឬក៏និយាយ"ខុស" បើទោះជានិយាយ"ខុស"ក្តី ក៏គ្មានទោសពៃរ៍អ្វីដែរ ហេតុអ្វីក៏នៅភ្នំពេញអ្នកនិយាយ"ខុស"ត្រូវមានទោសដល់ជាប់គុក? ម៉ាណែត បានប្រៀបធៀបសេរីភាពនិយាយស្តីខ្មែរទៅនឹងអាមេរិកថា មានដូចគ្នា តែច្បាប់ខ្មែរមានចែងពីអំពើឧក្រិដ្ឋជាក់ស្តែង. ដែលអនុញ្ញាត

នៅអាមេរិក នឹងកាណាដា នេះ មានបេសកកម្មផ្សព្វផ្សាយនយោបាយរបស់រដ្ឋាភិបាលខ្មែរ-របស់គណបក្សប្រជាជន- នឹងជ្រើសរើសក្រុមយុវជនថ្មីៗបន្ថែមទៀតឱ្យគណបក្សប្រជាជនផង... ក៏ប៉ុន្តែឧត្តមសេនីយ ហ៊ុន ម៉ាណែត ជាថ្នាក់ដឹកនាំចលនាយុវជននោះ បានទទួលស្គាល់ប្រាប់ "ឡូសាន់" ថា "ទស្សនៈកិច្ចរបស់លោកមិនបានជោគជ័យទេ" នេះការត្រឹមត្រូវមួយ ដែលថា "មានបាតុកម្មនៅគ្រប់ជំហ៊ានតាំងពីពេលមកដល់ឡុងបិច រហូតមកដល់ពេលបញ្ចប់ទស្សនកិច្ចចុងក្រោយបង្អស់ នៅឡូវែលនេះ"៕

RI Department of Labor and Training
Workforce Development Division
Business Workforce Center
*has partnered with for the*
State of Rhode Island
Department of Public Safety
COLONEL STEVEN G. O'DONNELL, COMMISSIONER

**RHODE ISLAND CAPITOL POLICE**
**2016 RECRUITMENT**
***From:* *04/17/16* *To:* *05/28/16***

PLEASE NOTE: THE DEPARTMENT OF PUBLIC SAFETY *WILL NOT* BE OFFERING AN ACADEMY FOR THIS PROCESS. SUCCESSFUL CANDIDATES *MUST* HOLD A VALID P.O.S.T (POLICE OFFICERS COMMISSION ON STANDARDS AND TRAINING) CERTIFICATE OR MUST BE ABLE TO OBTAIN A TRANSITIONAL P.O.S.T. CERTIFICATION FOR APPOINTMENT TO THIS POSITION.

**Capitol Police Officer Job Description:** Protects the State Capitol and annexes, properties, and the adjacent state buildings, grounds and premises against the ordinary hazards of trespass, theft, fire and damage; maintains order on the premises; protects employees and the public while on the premises; provides various levels of security screening and law enforcement services in the thirteen (13) buildings throughout the state; performs related work as required

CANDIDATES MUST POSSESS ALL OF THE FOLLOWING SPECIAL REQUIREMENTS PRIOR TO APPOINTMENT
- Physically qualified to perform assigned duties as evidenced by a physician's certificate;
- Submit to a full background criminal investigation;
- Meet the State of Rhode Island qualification requirements to carry weapons used in the performance of duty;
- Possess a valid Rhode Island Operator's Driving License;
- Have NO body piercings or tattoos that may be visible while in Department uniform.

FOR A MORE COMPREHENSIVE OVERVIEW, VISIT
www.capitolpolice.ri.gov/recruitment
State of Rhode Island is an Equal Opportunity/Diversity Employer

TO APPLY PLEASE SUBMIT APPLICATION MATERIALS AT
WWW.APPLYRI.GOV

Administrative Offices: 1511 Pontiac Avenue, Cranston, RI 02920
Equal Opportunity Employer-Auxiliary Aids and services available upon request to individuals with disabilities. TTY via RI Relay 711

តមកពីទំព័រទី ០២
## ប្រវត្តិចូលឆ្នាំខ្មែរ...

មានប្រាជ្ញា-អំណាច-ខ្លាំង ពូកែពុំអាចចាញ់នរណាបានទេ។ ដូច្នេះក្នុងរយៈពេល៥០ឆ្នាំនៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ មានការបណ្តុះបណ្តាលទ្រឹស្តីព្រះពុទ្ធសាសនាដល់ប្រជាពលរដ្ឋខ្មែរបានយ៉ាងជ្រាលជ្រៅពិធីបុណ្យចូលឆ្នាំតាមបែបព្រះពុទ្ធសាសនាលាយគ្នានឹងសាសនាមហាយានបែបនិកាយ"ពេជ្រយាន"បានត្រូវអនុវត្តន៏នឹងរក្សាយ៉ាងខ្ជាប់ខ្ជួន រហូតដល់រជ្ជកាលក្រោយបន្ទាប់មកដែលគេត្រឡប់ទៅកាន់ព្រហ្មញ្ញសាសនាវិញ ក៏ទំនៀមទម្លាប់ចូលឆ្នាំមិនបានប្រែប្រួលទៅណាទេ។


ប្រគេនចង្ហាន់ព្រះសង្ឃវត្តពន្លឺពុទ្ធិចក្រថ្ងៃចូលឆ្នាំខ្មែរ

ចំណែកឯរឿងដើមនៃពិធីចូលឆ្នាំ ក៏មានលំនាំដូចគ្នានឹងការប្រកួតកម្លាំងសាសនាដែរ រឿងនិទានថា កលិលមហាព្រហ្មជាស្តេចចក្រវាលមានមុខ៤ ដៃ៨ កាន់អាវុធគ្រប់ធុនត្រួតត្រាពីឋានលើមក, លើទេវនឹងទេវតានឹងមនុស្សសត្វទាំងអស់។ ថ្ងៃមួយព្រះអង្គឮថា នៅឋានកណ្តាលមានមាណពម្នាក់មានប្រាជ្ញាវាងវៃ ពូកែ ហើយជាអវតានៃព្រះពុទ្ធទៀតផង។ ឮដូច្នោះក៏ស្រូតចុះពីឋានលើមកជួបមាណពនោះនៅពេលគាត់ដើរទៅធ្វើស្រែ ដើម្បីសាកល្បងប្រាជ្ញា។ មាណពនោះមិនបានដឹងជាមុនថា ព្រះឥន្ទ្រាធិរាជមករកជួបខ្លួនទេ ប៉ុន្តែគាត់ចេះស្តាប់ភាសាសត្វដែលព្រះព្រហ្មមិនដឹង។ ពេលជួបមាណពនៅតាមផ្លូវ ហើយ ព្រះព្រហ្មបានតាំងសំនួរថា "ឡាលមាណព! យើងបានឮថាអ្នកមានចំណេះខ្ពង់ខ្ពស់ដឹងអស់សព្វសារពើ, ដូច្នេះសូមអ្នកឆ្លើយនឹងសំនួរយើងមួយ, តើពេលព្រឹករាសីមនុស្សនៅឯណា? ពេលថ្ងៃត្រង់រាសីនៅឯណា? ហើយពេលព្រលប់រាសីនៅឯណា? មាណពតបថា"បរពិតព្រះព្រហ្មដ៏ចំរើនអើយ! ទូលព្រះបង្គំជាប្រជារាស្ត្រសាមញ្ញម្នាក់មិនអាចនឹងប្រគួតប្រណាំងតាំងប្រស្នាជាមួយព្រះអង្គជាស្តេចចក្រវាលបានឡើយ..." ឮដូច្នោះព្រះព្រហ្មក៏មានបន្ទូលកាត់ថា"មាណពមិនបាច់ចាំឆ្លើយមកយើងនៅពេលនេះទេ, ថ្ងៃស្អែកយើងនឹងមកមកទីនេះម្តងទៀត ពេលនោះសិមអ្នកឆ្លើយនឹងសំនួរយើង" មិនត្រឹមតែប៉ុណ្ណោះព្រះព្រហ្មបន្តថា "បើអ្នកឆ្លើយនឹងសំនួរយើងត្រូវយើងនឹងកាត់ព្រះកេសាយើង ចុះចាញ់អ្នក! តែបើអ្នកឆ្លើយមិនត្រឹមត្រូវវិញ យើងនឹងកាត់ក្បាលអ្នកភ្លាម"មានព្រះបន្ទូលហើយ ក៏ហោះហើរចេញទៅបាត់។ មាណពស្រឡាំងកាំងភិតភ័យ ព្រោះមិនដឹងថា នឹងមានចម្លើយណាមួយថ្វាយព្រះឥន្ទ្រនោះទេរួចក៏ដើរត្រឡប់ទៅផ្ទះវិញទាំងសោកសង្រេង។ គាប់ជួនពេលនោះសត្វឥន្ទ្រីយមួយនៅលើចុងដើមឈើទាលមួយក្បែរនោះ បានឈើញព្រឹត្តិការណ៍នោះទាំងអស់។ យប់ឡើងមាណពដេកមិនលក់ទេ ដោយភ័យថា "ខ្លួនប្រាកដជាស្លាប់ក្រោមព្រះខាន់របស់ព្រះឥន្ទ្រនាព្រឹកស្អែកនោះហើយ" នឹកបណ្តើរដើរបណ្តើរទាំងទឹកភ្នែកទៅកាន់កន្លែងកើតហេតុពីព្រឹកមិញ, មិនអស់ចិត្តមាណពក៏ដង្ហោយថា"ឱអាត្មាអញអើយ! នឹងស្លាប់នៅថ្ងៃស្អែកនេះហើយព្រោះតែមិនមានចម្លើយថ្វាយព្រះព្រហ្ម"។ តទៅទំព័រទី ២៩



តាំងភ្នំខ្សាច់នៅមុខវត្តពន្លឺពុទ្ធចក្រ







## ចូលចិត្តមនុស្ស!

នេះជាមូលហេតុដែលនាំឲ្យ Fallon Health បានបើកដំណើរការ Summit ElderCare® ក្នុងទីក្រុង Lowell—ដើម្បីឲ្យយើងខ្ញុំអាចជួយដល់មនុស្សជាទីស្រឡាញ់ មិត្តភ័ក្ត និងអ្នកជិតខាងរបស់លោកអ្នក ឲ្យអាចរស់នៅបានដោយឯករាជ្យ និងអាចរស់នៅក្នុងផ្ទះរបស់ខ្លួនបានក្នុងពេលមួយដ៏យូរដែលអាចធ្វើទៅកើត ។

Summit ElderCare គឺជាកម្មវិធីដែលរួមបញ្ចូលការថែទាំសុខភាពគ្រប់យ៉ាង ចំពោះមនុស្សចាស់ (Program of All-Inclusive Care for the Elderly -PACE) ដែលមានផ្តល់ជូនសេវាកម្មវេជ្ជសាស្ត្រ, ការជ្រោមជ្រែងផ្នែកសង្គមកិច្ច, ការធានារ៉ាប់រងសុខភាព និងការថែទាំតាមផ្ទះ ដើម្បីជ្រោមជ្រែងមនុស្សចាស់ ដែលចង់បន្តការរស់នៅក្នុងផ្ទះរបស់ខ្លួន ។

**សូមហៅទូរស័ព្ទដើម្បីមកទស្សនាមជ្ឈមណ្ឌល PACE Center ថ្មីរបស់យើងខ្ញុំដែលមានទីតាំងនៅក្នុងបរិវេណសហគមន៍ D'Youville Life & Wellness Community នៃទីក្រុង Lowell ។**

### យើងខ្ញុំជឿជាក់ថា លោកអ្នកពិតជា~~ចូលចិត្ត~~ស្រឡាញ់មជ្ឈមណ្ឌលនេះ!

## Summit ElderCare

**1-866-737-9438 (TRS 711 – សម្រាប់អ្នកពិបាកស្តាប់)**

ថ្ងៃច័ន្ទ–សុក្រ, ពីម៉ោង 8 ព្រឹក–ម៉ោង 5 ល្ងាច

**summiteldercare.org/khmer**

fallonhealth

*គ្រប់សេវាកម្មថែទាំសុខភាពទាំងអស់ត្រូវតែផ្តល់ជូនដោយ ឬត្រូវបានអនុញ្ញាតដោយក្រុមពហុវិស័យរបស់ PACE (PACE Interdisciplinary Team) (លើកលែងតែចំពោះសេវាកម្មសង្គ្រោះបន្ទាន់) ។ សមាជិករបស់ PACE អាចត្រូវទទួលខុសត្រូវចំពោះការចំណាយណាមួយដែលមិនបានទទួលការអនុញ្ញាត ឬដែលនៅក្រៅកិច្ចព្រមព្រៀងសេវាកម្ម PACE ។*

16-679-019b_KH Rev. 00 2/16 AH12_16

# ប្រារព្ធពិធីបុណ្យវប្បធម៌អាស៊ីអាមេរិកឆ្នាំ ២០១៦

អត្ថបទដោយ ខេយឡា ចាន់
ប្រែសម្រួលដោយ សុខា


Kayla Chan

ទស្សនិកជនជាច្រើនបានអញ្ជើញទៅគាំទ្រមើលការសម្តែងនៅសាលសម្តែងសិល្បៈឌឺហ្គិន ឯសាលាយូម៉ាស ។ នេះឆ្នាំទី១៨ ហើយដែលសាលាយូម៉ាសបានប្រារព្ធនូវពិធីបុណ្យវប្បធម៌អាស៊ីអាមេរិក។ ការសម្តែងបានរួមបញ្ចូលទាំង របាំប្រពៃណី វប្បធម៌ខ្មែរ ពីក្រុមរបាំអង្គរការសម្តែងសិល្បៈសហសម័យរបស់ផលិតកម្ម ហ្លាយអឹងអប



និងការប្រគុំតន្ត្រីពីក្រុមតតន្ត្រីពិភពលោករបស់សាលាយូម៉ស ។

ទស្សនីយភាពបើកកម្មវិធីគឺជាការសម្តែងព្រាបសដែលបង្ហាញសមត្ថភាពសម្តែងដោយក្រុមរបាំអង្គរកុមារ ។ ទីពីរគឺការសម្តែងដាំដុះបន្លែបង្កាដែលជាទម្រង់ពីចាស់បុរាណ ហើយចុងក្រោយគឺការសម្តែងរឿងរាមកេរ្តិ៍ ដែលជាការសម្តែងដកស្រង់ចេញពីស្នាដៃដើមនៃរឿងរាមកេរ្តិ៍ដែលយកត្រង់វគ្គការសាកល្បងនាងសីតា និងព្រះអគ្គី ។ ចប់វគ្គទីមួយទស្សនិកជន សម្រាកសម្រួលឥរិយាបថរង់ចាំវគ្គទី២ ។ វគ្គទីពីរឈានមកដល់គឺជាការសម្តែងពីសិល្បករមកពីផលិតកម្ម ហ្លាយអ៊ីងអប ដែលដំបូងបានបង្ហាញនូវភាពយន្តខ្លីមួយមានចំណងជើងថា "ប្រអប់ចងចាំ" ជារឿងដែលនិយាយពីខ្សែជីវិតរបស់ចន្ទ្រាស្ត្រី ដែលបានរួចរស់ជីវិតពីសម័យខ្មែរក្រហម ។

ក្នុងចំណោមការសម្តែងទាំងអស់ខ្ញុំពេញចិត្តការសម្តែងសាច់រឿង "ប្រអប់ចងចាំ" ខ្លាំងជាងគេ។ ខ្ញុំមានសេចក្តីសប្បាយរីករាយទស្សនាភាពយន្តខ្លីនៃរឿងប្រអប់ចងចាំនេះ មុនពេលដែលសិល្បករសម្តែងផ្ទាល់ក្នុងឆាកសម្តែង ។ ការសម្តែងរឿងប្រអប់ចងចាំរបស់ផលិតកម្ម ហ្លាយអ៊ីងអប បោះធ្វើឱ្យសិល្បខ្មែរ បោះជំហានរីកចំរើនបន្ថែមទៀត ដែលប្រើបច្ចេកទេសថ្មីក្នុងការរៀបរាប់រឿងរ៉ាវអតីតកាល ។ ការសម្តែងមានសំភារៈសិល្បៈលាយឡំនឹងសម្លៀកបំពាក់តុបតែងទាក់ភ្នែក ឆាកសម្តែងដ៏អស្ចារ្យ និងភាសានិយាយជាគ្រាមភាសាខ្មែរដែលធ្វើឱ្យទស្សនិកជនកាន់តែផ្តោតអារម្មណ៍ទស្សនា និងចាំស្តាប់ទ្វេឡើង ។ រឿងនេះបានរំលឹងឡើងវិញនូវជីវិតដែលបានបាត់បង់ដោយគ្មានកំហុសក្នុងរបបសម្លាប់រង្គាលនៃប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជា ។

ទស្សនីយភាពនាថ្ងៃនោះ និងការប្រារព្ធនូវពិធីបុណ្យវប្បធម៌អាស៊ីអាមេរិកជាព្រឹត្តិការណ៍ដែលនាំឱ្យមានការជួបជុំគ្នានៃប្រជាជនក្នុងសហគមន៍ ហើយទស្សនិកជនមានគ្រប់ស្រទាប់អាយុទាំងចាស់ ទាំងក្មេង ទាំងខ្មែរសុទ្ធ និងខ្មែរអាមេរិកាំង និងរួមចម្រុះជាតិសាសន៍បានស្វែងយល់មួយផ្នែកពីប្រវត្តិនិងសិល្បខ្មែរ ហើយតម្លៃសំបុត្រគឺចំណាយមិនស្តាយឡើយ ត្រឹមតែ ១០ដុល្លារប៉ុណ្ណោះ ដូចនេះសូមកុំភ្លេចអញ្ជើញទស្សនានៅឆ្នាំក្រោយ ៕

# Asian American Cultures Festival 2016

**by Kayla Chan**

The Durgin Hall auditorium was filled on a Friday night as UMass Lowell hosted its annual Asian American Cultures Festival on April 18th. The event featured performances by Angkor Dance Troupe, Flying Orb Productions, and the UMass Lowell World Music Ensemble. The Angkor Dance Troupe had three performances. The first being a classical dance called the White Dove dance, which featured the troupe's youngest female dances. The second was the Good Crop dance, which a folk dance. The final performance was a scene from Reamker, which is the troupe's original production of the Cambodian version of the Ramayna story, entitled Neang Seda and the Test of Fire. Following an intermission, the Flying Orb Productions presented a short film and live performance of the Memory Box, which is a tale about Chantrea, a survivor of the Khmer Rouge.

Of all the performances, I found the Memory Box the most interesting. I enjoyed how the film gave a brief synopsis of the tale before the live performance, which took a modern approach in storytelling. The performers used dance and movement to act out characters, scenes, and props. There were few spoken lines, which made the audience pay extra attention to the actors. Overall, it was a very captivating and emotional performance. It paid tribute to some of the victims of the Khmer Rouge and the emotional performance even made audience members to tear up.

What I liked the best about the event was that it brought people of different backgrounds together. The audience was filled with the young, the old, and people of different ethnicities. This collection of people was also represented within the performers. The students in the UMass Lowell World Music Ensemble learned how to play traditional Asian instruments and provided the live music for the dance performances. To my untrained ear, the students' accompaniment to the performances sounded flawless. The event brings people together and gives the opportunity to learn about Asian cultures. It gives attendees a background of history, but also displays the evolvement since. The incredible performances are worth attending, and tickets are only $10. If you get the chance to go next year, I would recommend it.


Clemente Park Chiropractic


Chetra A. Keo, D.C.

851 Middlesex Street. Lowell, MA 01851
(978) 937-1492

Treatments
- Neck Pain • ឈឺក
- Back Pain • ឈឺខ្នង
- Lower Back Pain • ឈឺចង្កេះ-ខ្នង

- Automobile Injuries • គ្រោះថ្នាក់រថយន្ត
- Personal Injuries • រងរបួស
- Work Related Injuries • របួសនៅកន្លែងធ្វើការ






The Greater Merrimack Valley
History + Natural Beauty!
What's YOUR Next Adventure?
merrimackvalley.org
MASSACHUSETTS massvacation.com
Greater Merrimack Valley Convention and Visitors Bureau merrimackvalley.org

# ស្ត្រីសកម្មជនដើម្បីសន្តិភាពមកឡូវែល

**អត្ថបទដោយ សុខា**

**ប្រភពអត្ថបទ និងរូបភាព ពីយូម៉ាសឡូវែល**







លោកស្រី សាណាំ ណារ៉ាហ្គី អាន់ដឺលីនី (Sanam Naraghi-Anderlini) បានអញ្ជើញមកដល់ឡូវែលធ្វើបទបង្ហាញចែកបទពិសោធន៍របស់លោកស្រីមកដល់សហគមន៍ឡូវែល។ ក្នុងនោះ លោកស្រីបានធ្វើបទបង្ហាញទាំងក្នុងថ្នាក់រៀននៃសាលាយូម៉ាស ព្រមទាំងមកធ្វើបទបង្ហាញនៅឯបន្ទប់សន្និសីទនៃមជ្ឈមណ្ឌលសុខភាពក្រុងឡូវែល។

លោកស្រីមានដើមកំណើតជាជាតិអ៊ីរ៉ង់ ទទួលការសិក្សាពីចក្រភពអង់គ្លេស និងបានបម្រើការងារនៅក្នុងអង្គការសហប្រជាជាតិអស់ជាច្រើនឆ្នាំ។ លោកស្រីមានបទពិសោធន៍ផ្តល់ការបណ្តុះបណ្តាល និងតស៊ូមតិដើម្បីសន្តិភាពក្នុងពិភពលោក និងបង្ហាញឱ្យឃើញពីតួនាទីស្ត្រីដើម្បីសន្តិភាព។ លោកស្រីធ្លាប់បំពេញការងារជាមួយស្ត្រីដឹកនាំជាច្រើនក្នុង១២ប្រទេសក្នុងមជ្ឈិមបូពារ និងអាហ្វ្រិក។ ក្នុងនោះលោកស្រី ក៏មានការស្ញើចសរសើរនូវការតស៊ូ និងការបំពេញតួនាទីរបស់អ្នកស្រី មូ សុខហួ តំណាងរាស្ត្រស្ត្រីខ្មែរ ។

លោកស្រី អានដឺលីនី គឺជាអ្នកនិពន្ធសៀវភៅផងដែរ។ ស្នាដៃនាងរួមមានសៀវភៅស្ត្រីកសាងសន្តិភាព។ ក្រៅពីនេះ លោកស្រីជាស្ថាបនិក និងនាយកប្រតិបត្តិនៃសម្ព័ន្ធចលនាសហគមន៍អន្តរជាតិហៅកាត់ថា អាយខេន (ICAN) ដែលមានទីស្នាក់ការនៅរដ្ឋធានីវ៉ាស៊ីនតោន៕


NOVUS TIMELESS MEDSPA & SKINCARE

ហាងស្ប៉ាកែសម្ផស្ស និងរក្សាស្បែកឡូស – Watertown Square




BOTOX (ចាក់សារធាតុពន្យារវ័យលើផ្ទៃមុខ មិនបាច់វះកាត់) - ធ្វើម្តង (per treatment) No surgery / No Downtime

- បំបាត់ស្នាមជ្រួញ / ខ្សែជុំវិញភ្នែក (Crow feet wrinkles/lines Reduction)..$168 (តម្លៃចាប់ពី $250)
- បំបាត់ខ្សែ/ជ្រួញលើថ្ងាស (Forehead wrinkles/lines Reduction)............$218 (តម្លៃចាប់ពី $299)
- លើកសាច់មុខធម្មជាតិទាំងមូល (Natural Face Lift for whole face) ........$588 (តម្លៃចាប់ពី $888)
- បន្តឹងស្បែកមុខធម្មជាតិទាំងមូល (Skin tightening for whole face) ..........$588 (តម្លៃចាប់ពី $888)

DERMAL FILLERS(ចាក់ផ្ទៃមុខ មាត់ និងចង្កា មិនបាច់វះកាត់) -- ធ្វើម្តង (Per treatment) No surgery/no downtime

- លើកខ្ទង់ច្រមុះ (Nose Bridge Procedure)..........................................$888 (តម្លៃចាប់ពី $1200)
- ចាក់ចង្កា (Chin enhancement / augmentation)..................................$888 (តម្លៃចាប់ពី $1200)
- លើកសាច់មុខធម្មជាតិទាំងមូល (Natural Face Lift for whole face)......... $588 (តម្លៃចាប់ពី $888)
- ចាក់ចង្កាពីរជាន់ (Double Chin reduction)..........................................$988 ( តម្លៃចាប់ពី$1200)
- ចាក់បបូរមាត់ (Lip augmentation)......................................................$788

បំបាត់ស្នាម/មុន/ជ្រួញ/កាត់ប្រជ្រុយ (Removal of scars/pimples/ wrinkles/spots. បន្តឹង និងធ្វើឲ្យស្បែកសជាងមុន Whitening&Tightening)

- បាញ់កម្មរស្មីរូបមន្តធ្យូងថ្មខ្មៅ (Black CharcoalLaser Therapy)...... $168/1ដង,$768/5ដង, $1280/10ដង( តម្លៃទូទៅ $388/1ដង)
- បកកោសិកាចាស់ ដោយបច្ចេកវិទ្យាប្រទេសកូរ៉េ (Organic SMAS Phytozen Korean Peels)......$168/1ដង,$768/5ដង, $1280/10ដង( តម្លៃទូទៅ $388/1ដង)
- សម្រកទម្ងន់ (Weight loss )............................$168/1 ដង, $780/5ដង, $1280/10 ដង( តម្លៃទូទៅ $388/1ដង)

សូមទូរស័ព្ទមក ខារីណា ស៊ូ

617-923-9888



Carina Su, RN

2 Mt Auburn St, Watertown, MA, 02472

The 6th Annual

KhmerPost USA ខ្មែរផុស

# សេចក្តីអញ្ជើញ

## ជូនចំពោះបងប្អូនខ្មែរក្នុងសហគមន៍

ខែឧសភា គឺជាឱកាសនៃការប្រារព្ធពិធីបេតិកភ័ណ្ឌជាតិអាស៊ាន និងប៉ាស៊ីហ្វិក អាមេរិកាំង។ សារព័ត៌មានខ្មែរផុស មានសេចក្តីសោមនស្សរីករាយគោរពអញ្ជើញលោក លោកស្រីអ្នកនាងកញ្ញាលោកតា លោកយាយ លោកអ៊ំ លោកពូ អ្នកមីង ចូលរួមក្នុងកម្មវិធីរាត្រីសមោសរប្រចាំឆ្នាំលើកទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ សុក្រទី២០ ខែឧសភា ឆ្នាំ២០១៦ ចាប់ពីម៉ោង៥:៣០នាទីរសៀល រហូតដល់ម៉ោង១០យប់។ យើងខ្ញុំនឹងអបអរសាទរ "ចំណងមេត្រីភាពនៃវប្បធម៌ចម្រុះ" ក្នុងទីក្រុងឡូវែល។ ពិធីនេះនឹងប្រព្រឹត្តទៅនៅរង្គសាល សំពៅមាស ផ្លូវ៤៥០ Chelmsford ក្នុងក្រុងឡូវែលនៃរដ្ឋម៉ាសាឈូសេត។ តម្លៃសំបុត្រ $45 សម្រាប់ភ្ញៀវម្នាក់ និង $400 សម្រាប់ភ្ញៀវ១០នាក់។

ឆ្នាំនេះយើងរីករាយក្នុងការបង្កើតភាពជាដៃគូជាមួយសភាពាណិជ្ជកម្មក្រុងឡូវែល និងមណ្ឌលសិក្សា វប្បធម៌អាស៊ីអាមេរិកាំងនៃសាកលវិទ្យាល័យរដ្ឋម៉ាសាឈូសេត ឡូវែល (យូម៉ាសឡូវែល)។ បុព្វហេតុនៃកម្មវិធីនេះ គឺដើម្បីពង្រីក និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីភាពចំរុះនៃជាតិសាសន៍ទាំងឡាយក្នុងសង្គមអាស៊ីអាមេរិកាំងដែលប្រាស្រ័យការរស់នៅទាំងក្នុងសហគមន៍ឡូវែល និងទីដទៃទៀត។ កម្មវិធីនៃរាត្រីនោះ នឹងរួមបញ្ចូលទាំងការសម្តែងវប្បធម៌ភ្ជាប់ទៅនឹងការពិសាភោជនីយហារ។ វេទិកាសម្រាប់សុន្ទរកថា នឹងចាប់ផ្តើមនៅម៉ោង៧:៣០នាទីល្ងាច ហើយកម្មវិធីនេះនឹងបញ្ចប់នៅម៉ោង១០យប់។ ឆ្នាំមុនយើងខ្ញុំមានសេចក្តីសប្បាយរីករាយជាពន្លឹកដែលមានភ្ញៀវកិត្តិយសអញ្ជើញចូលរួមលើសពី៣០០នាក់។

យើងខ្ញុំសូមថ្លែងអំណរគុណលោកអ្នកដែលបន្តគាំទ្រ និងកំពុងសម្រេចចិត្តផ្តើមធ្វើជាអ្នកឧបត្ថម្ភកម្មវិធី នាឆ្នាំនេះ។ សូមអរគុណលោកអ្នកដែលបានចំណាយពេល និងពិចារណាធ្វើជាអ្នកឧបត្ថម្ភ។

សូមអញ្ជើញទាក់ទងសុបិន្ត ពិន (978) 656 8141, រ៉ជឺ សំខុន ពិន (978) 942 1641 សូមអរគុណ!



ពិន សុបិន្ត, នាយកគ្រប់គ្រង



ពិន សំខុន, និពន្ធនាយក

# ឆ្នាំ ២០២២ កាលីហ្វនីញ៉ានឹងមានប្រាក់ឈ្នួលអប្បបរមា $15

**រៀបរៀងដោយ ហង្ស តារាយុទ្ធ**

រដ្ឋកាលីវ៉ៃលញ៉ា (California) បានក្លាយទៅជារដ្ឋដំបូងគេដែលព្រមព្រៀងដំឡើងប្រាក់ឈ្នួលអប្បរមា ១៥ដុល្លារក្នុង១ម៉ោង។

កាលពីថ្ងៃព្រហស្បតិ៍ ទី៣១ ខែមីនា ឆ្នាំ ២០១៦ រដ្ឋសភា និងព្រឹទ្ធសភា បានព្រមព្រៀងអនុម័តនូវវិធានការដំឡើងប្រាក់ឈ្នួលអប្បរមាដល់ ១៥ដុល្លារក្នុងមួយម៉ោង។ លោក អភិបាលក្រុង ជើរព្រៅន (Jerry Brown) បានមានប្រសាសន៍ថា គាត់នឹងចុះហត្ថលេខាទៅលើវិធានាការនោះ នាថ្ងៃច័ន្ទ ទី០១ខែ មេសា ឆ្នាំ២០១៦ នេះ។

វិធានាការនេះ នឹងបង្កើននូវប្រាក់ឈ្នួលអប្បរមាពី១០.៥០ដុល្លារ នៅក្នុងខែមករា ទៅដល់១១ដុល្លារ នៅខែមករា ឆ្នាំ២០១៨។ វានឹងបន្តបង្កើនថែម១ដុល្លាររាល់ឆ្នាំ រហូតដល់ប្រាក់ឈ្នួលអប្បបរមាកើនដល់១៥ដុល្លារក្នុងឆ្នាំ ២០២២។ ប៉ុន្តែអភិបាលក្រុងអាចមានសិទ្ធិពន្យឺតពេលក្នុងការអនុវត្តនីតិវិធីនេះប្រសិនបើរដ្ឋមានបញ្ហាផ្នែកសេដ្ឋកិច្ច ឬក៏បញ្ហាផ្នែកគំរោងថវិកា។

ទីក្រុងឡូសអេជេលេស (Los Angeles) បានយល់ស្របបង្កើននូវប្រាក់ឈ្នួលអប្បរមាដល់១៥ដុល្លារក្នុងមួយម៉ោងត្រឹមឆ្នាំ២០២០ធ្វើឱ្យទីក្រុងនេះខ្លាចជាទីក្រុងដ៏ធំបំផុតនៅក្នុងប្រទេសនេះ។ រីឯសានហ្វ្រាន់ស៊ីស្កូ (San Francisco) គ្រោងបង្កើននូវប្រាក់ឈ្នួលអប្បបរមាដល់១៥ដុល្លារត្រឹមឆ្នាំ២០១៨។ រីឯទីក្រុងរបស់រដ្ឋកាលីហ្វញ៉ាដទៃទៀត រួមបញ្ចូលទាំង សេន ឌីអាហ្គូ (San Diego) និង អូកលេន (Oakland) ក៏បានយល់ស្របក្នុងការបង្កើននូវអប្បរមាប្រាក់ឈ្នួលរបស់ខ្លួនផងដែរ។

ថ្មីៗនេះប្រាក់ឈ្នួលអប្បរមាទូទាំងរដ្ឋកាលីហ្វញ៉ាទាំងអស់បានបង្កើនឱ្យដល់១០ដុល្លារក្នុងមួយម៉ោង គឺជាអប្បរមាដ៏ខ្ពស់បំផុតនៅក្នុងប្រទេស។ ស្របជាមួយគ្នានេះ ប្រាក់ឈ្នួលអប្បរមាក្នុងរដ្ឋកាលីហ្វញ៉ា ស្មើទៅនឹងរដ្ឋម៉ាសាឈូសេត (Massachusete) ហើយតម្លៃនេះ គឺស្ថិតនៅបន្ទាប់ពីវ៉ាស៊ីនតុនឌីស៊ី (Washington DC) ដែលមានអប្បរមាប្រាក់ឈ្នួលចំនួន១០.៥០ដុល្លារ បើយោងទៅតាមក្រុមប្រឹក្សានៃសភាជាតិ ៕



អភិបាលរដ្ឋកាលីហ្វនីញ៉ា










AccuCare
Home Care Agency
Group Adults Foster Care Program

## កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។*

**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
- រស់នៅផ្ទះរដ្ឋ
  អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**
- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**
- live in subsidized or public housing
- age 22 years and older
- eligible for Masshealth Standard

**Benefits you will get:**
- personal care service in your home,
- Medication Managemant
- an individual care plan developed by a registered nurse and case manager
- ongoing monitoring of needs
- 24-hour access to services

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# អត្ថប្រយោជន៍ដ៏សំបូរបែប របស់ក្រូចថ្លុងក្រហម

ជាការពិតណាស់ថា ក្រូចថ្លុងក្រហមល្អមានអត្ថ-ប្រយោជន៍ចំពោះប្រព័ន្ធរំលាយអាហារជួយបញ្ចុះទម្ងន់ និងនៅមានផលប្រយោជន៍ជាច្រើនទៀត ដោយសារវាមានប្រមាណ៩ភាគរយនៃអាស៊ីដស៊ីទ្រិក១៤ភាគរយនៃជាតិស្ករ ប៉ូតា ស្យូម ហ្វូសហ្វ័រ កាល់ស្យូម ពពួកវីតាមីន C, A, B1 ។ ក្រូចថ្លុងអាចព្យាបាលជំងឺមួយចំនួនដូចតទៅនេះ :



**+បញ្ចុះទម្ងន់ :**

ការសិក្សាថ្មីបានរកឃើញថា ការបន្ថែមក្រូចថ្លុងក្រហមទៅក្នុងរបបអាហារប្រចាំថ្ងៃវានឹងអាចជួយបញ្ចុះទម្ងន់បានយ៉ាងមានប្រសិទ្ធភាព ។

**+គ្រុនក្តៅ និងជំងឺផ្តាសាយ ធូរស្រាលៈ**

ទឹកក្រូចថ្លុងក្រហមជួយអ្នកជំងឺឱ្យមានសុខភាពល្អឡើងវិញក្រោយកើតជំងឺគ្រុនក្តៅបន្ថយអារម្មណ៍ក្តៅរោលរាលដោយសារសីតុណ្ហភាពសរីរាង្គឡើងខ្ពស់ និងជាឱសថដ៏មានតម្លៃចំពោះជំងឺគ្រុនផ្តាសាយ ។

**+ប្រឆាំងមហារីក :**

ការផឹកទឹកក្រូចថ្លុងក្រហម៥៣០មិល្លីលីត្រក្នុងមួយថ្ងៃនឹងធ្វើឱ្យសកម្មភាពរបស់ CYPIA2 ដែលជាអង់ហ្ស៊ីមមួយរំញោចសកម្មភាពរបស់សារជាតិគីមីបង្កជំងឺមហារីកក្នុងផ្ទៃរងបារីថយចុះគួរឱ្យកត់សម្គាល់ ។ ក្រៅពីនេះ ក្រូចថ្លុងក្រហមសម្បូរសារជាតិ Flavonoid មានឥទ្ធិពលដូចជាសារជាតិប្រឆាំងអុកស៊ីតកម្មធម្មជាតិការពារ និងទប់ស្កាត់សកម្មភាពរបស់ពពួកសារជាតិបង្កមហារីក ។ ក្រូចថ្លុងក្រហមផ្ទុកបរិមាណ Lycopene ខ្ពស់ជួយប្រឆាំងអុកស៊ីតកម្មរួមចំណែកធ្វើឱ្យថយចុះគ្រោះថ្នាក់មហារីកក្រពេញប្រូស្តាត ។

**+សម្រួលដល់ប្រព័ន្ធរំលាយអាហារៈ**

ក្រូចថ្លុងក្រហមមានប្រយោជន៍បំផុតក្នុងការដោះស្រាយបញ្ហាហើមពោះ ពិបាករំលាយអាហារ វាធ្វើឱ្យថយចុះកម្តៅ និងរំញោចសកម្មភាពរបស់ក្រពះកែប្រែឱ្យប្រសើរចរន្តហូររបស់រំអិលរំលាយអាហារជួយសរីរាង្គរំលាយអាហារល្អជាង ។

**+ការទល់លាមក :**

ផឹកទឹកក្រូចថ្លុងក្រហមស្រស់មួយកែវនៅពេលព្រឹកជាឱសថ ល្អបំផុតដើម្បីគ្រប់គ្រងអាការៈទល់លាមក ។ ក្រូចថ្លុងក្រហមពង្រីកប្រសិទ្ធភាពក្នុងការរំញោចពោះវៀនធំ និងបណ្តាផ្នែកដទៃទៀតរបស់សរីរាង្គរារាំងការកើតអាការៈទល់លាមក ។

**+ជំងឺទឹកនោមផ្អែមៈ**

អ្នកជំងឺទឹកនោមផ្អែមគួរបរិភោគក្រូចថ្លុងក្រហមមួយផ្លែក្នុងមួយថ្ងៃ។ ការបរិភោគក្រូចថ្លុងអាចរារាំងបរិមាណម្សៅបញ្ចូលទៅក្នុងសរីរាង្គហេតុនេះជួយបន្ថយក្តីបារម្ភអំពីជំងឺទឹកនោមផ្អែម ៕


## MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229



- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលនទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com

## Red Rose RESTAURANT
ភោជនីយដ្ឋាន ក្លាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm




* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400










# លិខិតជូនទៅសហគមន៍ពីក្រុមប្រឹក្សាក្រុងឡូវែល

## រីតាមឺស្សេរ

**បកប្រែដោយ ហង្ស តារាយុទ្ធ**

**សម្រួលអត្ថបទដោយ សុខា**



ដំបូងបង្អស់ខ្ញុំចង់និយាយថាខ្ញុំមិនដែលឆ្លើយតប ឬក៏អាននូវទំព័រប្លក់អ្វីទាំងអស់។ យ៉ាងណាមិញពីប្រភពមួយដែលខ្ញុំទទួលបានគេបានប្រាប់ខ្ញុំអំពីសំណេររបស់ ជើរី នុតធី(Jerry Nutter) ដែលបានវិភាគទៅលើការបោះពាក្យសម្ដីធ្ងន់ៗ របស់អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា លោក ផាយ ស៊ីផាន់ (Phay Siphan) មកកាន់ខ្ញុំ ក្នុងនោះមានទាំងសម្ដីបង្កប់ការរើសអើងប្រកាន់ភេទ និងគ្មានតម្លៃការទូត។ ប្រជាជនបានផ្ញើរនូវញត្តិទាមទារឱ្យលោក ផាយស៊ីផាន់ ធ្វើការសុំអភ័យទោសចំពោះការកត់សំគាល់ទាំងនោះ។

អនុញ្ញាតិឱ្យខ្ញុំអរគុណលោក ជើរី ដែលបានឱ្យដំណឹងទៅអ្នកគាំទ្ររបស់គាត់អំពីព្រឹត្តិការណ៍ដែលបានធ្វើឡើងនៅសាលាក្រុង កាលពីថ្ងៃអង្គារសប្ដាហ៍មុន ព្រមទាំងអរគុណអ្នកដែលបានបញ្ចេញមតិក្នុងផ្លូវវិជ្ជមាន ហើយនឹងបានចុះហត្ថលេខាលើញត្តិនោះ។ សូមមេត្តាឱ្យអ្នកដឹងថា អ្នកមិនបានជំពាក់សគុនអ្វីទាំងអស់ជាមួយខ្ញុំ ប៉ុន្តែខ្ញុំពិតជាដឹងគុណអ្នកណាស់។

ការបន្ទុះបង្អាប់ដល់ឈ្មោះខ្ញុំមិនបានធ្វើឱ្យខ្ញុំឈឺចាប់ទេ។ យ៉ាងណាក៏ដោយអ្វីដែលធ្វើឱ្យខ្ញុំឈឺចាប់បំផុតនោះ គឺការកុហក ដែលថា ខ្ញុំគ្មានសមត្ថភាពរស់នៅជាមួយនិងជាតិសាសន៍ដទៃ។ ខ្ញុំធ្លាប់រស់នៅជាមួយនឹងមនុស្សដែលមានជាតិសាសន៍ខុសគ្នាដ៏អស្ចារ្យម្នាក់ ហើយគាត់នោះគឺជាឪពុករបស់ខ្ញុំដែលជាជនអន្តោប្រវេសន៍មានដើមកំណើតកើតជានៅប្រទេសប៉ូឡូញ(Poland) កាលនោះមកប្រទេសអាមេរិក ហើយរស់នៅក្នុងសហគមន៍ចំរុះសាស្ត្រប្រាំង់កូអាមេរិកកាំង និងចូលរៀននៅសាលាសាសន៍អាយរីសសាសនាកាតូលិក (Irish Catholic School) ។ ភាពចំរុះជាតិសាសន៍បានទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំនៅពេលដែលខ្ញុំមានអាយុតិច។ ខ្ញុំបានឃើញនូវមោទនភាពនៅក្នុងមនុស្សដែលមកពីប្រទេសដទៃ និងឃើញពួកគេនឹកទឹកដីកំណើតរបស់ពួកគេ ប៉ុន្តែរឿងនេះមិនធ្វើឱ្យពួកគេមានសម្ពាធអ្វីទាំងអស់។ វាជាទឡ្ហីករណ៍បង្ហាញឱ្យខ្ញុំឃើញថា ត្បិតពួកយើងមកពីប្រទេសដទៃមានប្រភពកំណើតដោយឡែកពីគ្នា ប៉ុន្តែយើងមាននូវគោលដៅដូចគ្នា និងសង្ឃឹមថា ទទួលបានស្មើរភាពគ្នាក្នុងការរស់នៅ។

អ្វីដែលខ្ញុំបានឃើញ កាលពីថ្ងៃអង្គារសប្ដាហ៍មុននៅកិច្ចប្រជុំ គឺជាប្រជាធិបតេយ្យដ៏ល្អបំផុត។ "បេះដូងរបស់ខ្ញុំពោរពេញដោយមោទនភាព ខណៈពេលដែលមនុស្សនិយាយនូវអ្វីដែលពួកគេជឿជាក់។ សូម្បីតែខ្ញុំគិតថា ខ្ញុំពិតជាសរសើរភាពក្លាហានរបស់ពួកគេទាំងនោះ ដែលហ៊ានបញ្ចេញទស្សនៈផ្សេងគ្នា។ ការធ្វើបែបនេះនឹងមិនត្រូវបានគេអត់ធ្មត់ទេនៅក្នុងប្រទេសកម្ពុជា។ ត្បិតខ្ញុំផ្ទាល់និងអតីតចៅហ្វាយក្រុង រូដនី អីលៀត(Rodney Elliott) បានឃើញផ្ទាល់នឹងភ្នែកអំពីការជាប់គុករយៈពេលជាច្រើនឆ្នាំរបស់ស្ត្រី១០អ្នកដែលត្រូវបានចោទថា ប្រព្រឹត្តបទឧក្រិដ្ឋក្នុងករណីទាមទារយកដីធ្លី និងផ្ទះដែលត្រូវបានគេរឹបអូសដោយអយុត្តិធម៌។

ខ្ញុំយល់ស្របជាមួយអ្នកនាំពាក្យរដ្ឋភិបាល នៅពេលគាត់និយាយថា ខ្ញុំជាអ្នកប្រកាន់បុរេវិនិច្ឆ័យ។ គាត់ពិតជានិយាយត្រឹមត្រូវ។ ខ្ញុំគឺជាអ្នកប្រកាន់បុរេវិនិច្ឆ័យចំពោះមនុស្សដែលបំពានសិទ្ធិអ្នកដទៃ ពុករលួយ និងរំលោភបំពានសិទ្ធមនុស្ស។ ខ្ញុំមានទស្សនបុរេវិនិច្ឆ័យផ្អែកលើការឈឺចាប់ទាំងឡាយដែលខ្ញុំបានឃើញថាកើតឡើងនៅប្រទេសកម្ពុជានៅពេលមនុស្សអាក្រក់ទមិឡ ឥតសាសនាផ្លាស់ប្តូរកែប្រែវិទ្យាល័យរបស់ប្រជារាស្ត្រស្លូតត្រង់ទៅជាគុកឃុំឃាំងធ្វើទារុណកម្មទៅលើបុរសម្នាក់នៅពេលដែលគេបដិសេធមិនសារភាពពីទីកន្លែងលាក់ខ្លួននៃគ្រួសាររបស់ពួកគេ។ ដោយមានការចងភ្ជាប់ដៃនៅពីក្រោយខ្នង ពួកគេបានងើបមកម្ដងហើយម្ដងទៀត នៅក្នុងទឹកដែលមនុស្សមួយចំនួនលង់ទឹកដោយសារព្យាយាមជួយនូវគ្រួសាររបស់ពួកគេ។ ខ្ញុំឃើញនូវ ឆ្អឹង និងខួរឆ្អឹង ជាច្រើនគរលើគ្នាជាលទ្ធផលពីការសម្លាប់រង្គាល។ អញ្ចឹងខ្ញុំមានទស្សនៈបុរេវិនិច្ឆ័យនៅពេលស្ត្រីត្រូវបានគេដាក់ទារុណកម្ម ជាពិសេសគឺការតាបនូវចុងដោះជាមួយនឹងឧបករណ៍ដ៏មុតស្រួច ដើម្បីបង្ខំឱ្យពួកគេប្រាក់អំពីកន្លែងលាក់ខ្លួននៃកូនរបស់គេ។ ខ្ញុំយំខណៈដែលខ្ញុំបានសរសេរនូវរឿងនៃស្ថានភាពដ៏អាក្រក់ **តទៅទំព័រទី ២៧**

# Letter from City Councilor Rita M. Mercier to the Community

**First let me say that I never respond to blog sites, let alone read them, but someone alluded me to the fact that Jerry Nutter had a particular interesting one where he reported that a Cambodian Government spokesman, Phay Siphan, made some insulting, sexist, racist and undiplomatic remarks about me and that people were forming a petition for an apology from him for those remarks.**

**Let me thank Jerry for informing his followers about the event that took place in city hall last Tuesday as well as thank the people who commented in a positive way and signed that petition. Please know you owe me nothing but again I am grateful.**

**Names do not hurt me. However, what hurt me was the lie that I have no capacity to live with diverse people. I have lived with a wonderful diverse person for many years, he was my father an immigrant, born in Poland, in a Franco American neighborhood, going to an Irish Catholic school. At a very young age diversity peeked my interest. I saw the pride in people who came from different countries and how they missed their homeland but not the oppression. It intrigued me as to how we could come from different lands and yet be the same, have the same goals and just expect to be treated fairly.**

**What I saw last Tuesday at the meeting was "Democracy at its very BEST". My heart swelled with pride as people spoke for what they believed in. I even thought how I admired the courage of those that spoke on the opposite view. This would not be tolerated in Cambodia. I know that, because former Mayor Rodney Elliott and I saw the jailing for over a year, of ten women, whose only crime was that of fighting for their land and homes which were taken unjustly from them.**

**I will agree with the government spokesman when he says that I am prejudice. He is perfectly right. I am prejudice….. to those that inflict harm on others, prejudice to those who are corrupt and violate people's human rights. I am prejudice to what I saw in Cambodia when their High School was turned into a prison where a huge wooden box was a torture chamber to men who would not reveal the location of the rest of their families. With their hands tied behind their backs they were submerged over and over again in the water to which many drowned to save their family. I saw the bones and skulls of the dead stacked high in a monument that overlooked the killing fields. So yes, I am damn prejudice when women were tortured, as well, by clipping off their nipples with a sharp instrument to make them tell where their children are. I cry as I write this for this horrendous situation actually happened and I saw pictures of the torture. So yes I am prejudice to these atrocities, where people left the country of their birth, that they loved in search of freedom. They journeyed many miles and eventually came here in Lowell. Having visited your beautiful country of Cambodia I feel that I know you better.**

**I am not the smartest or the best city councilor but I am FAIR and as long as the last breath is in me, whether I am a councilor or not I will still speak up for justice, just as I did when the lady called me with a problem with a $10,000 dollar water bill. She was the first to alert me and she was Cambodian. Because of her, she changed the billing practice. We now have new water meter boxes and people got fired because things were not done properly. This is the American way for which our veterans fought for and to whom I owe my greatest respect to.**

**Please know that I respect all people who do things right and respectful, if I can do it so can you and if the laws says I cannot do it then neither will you. It is all about being fair.**

**In closing let me say that I admire people who get involved in their community. The city council chair that I am sitting in each week is not mine, I just used it each week to deliver your message. The building that we were all in belongs to everyone, it is just as much yours as it is mine. So let it be known that I am so proud of your accomplishments Tuesday. Together we can make great things happen. Thanks, Rita M. Mercier**


សួស្តីឆ្នាំថ្មី ឆ្នាំវក នព្វស័ក ព.ស ២៥៦០ គ.ស ២០១៦
SATURDAY
30APRIL
6pm-12am
SPONSOR BY:
VANNAK MEN
ជួបជាមួយលោក យឹម យន (លោក កែវ សារ៉ាត់ ទី២)
តារាចម្រៀងមកពីព្រះរាជាណាចក្រកម្ពុជា ដែលជាឯកអគ្គរាជទូតមរតកខ្មែររបស់ IKARE
លោក Rak PS, អ្នកនាង ខាត់ ស្រីបង និង ក្រុមតន្ត្រី BAD-BOY
រាត្រីសំពៅមាស
SAMPAOMEAS RESTAURANT
450 CHELMSFORD ST. LOWELL MA. 01851
ADVANCE $15, AT THE DOOR $20
INFO CONTACT 978-328-4182, 978-893-6829
FLYER DESING: 857-205-9083

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# ការស៊ើបអង្កេតធ្វើឡើងលើការអះអាងនៃការវាយដំដោយអង្គរក្សរបស់ ម៉ាណែត

**ដោយ អេឡិក វិល្លែមមីនស៍** | April 18, 2016

នគរបាលក្នុងក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា បាននិយាយកាលពីថ្ងៃសៅរ៍ថា ខ្លួនបានបើកការស៊ើបអង្កេតទៅលើការចោទថាការវាយដំបុរសជាជនជាតិអាមេរិកាំងម្នាក់ដែលធ្វើឡើងដោយអង្គរក្សរបស់កូនប្រុសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោក ហ៊ុន ម៉ាណែត។

ប៉ុន្តែក្នុងបទសម្ភាសមួយនៅថ្ងៃដដែលនោះ ឧត្តមសេនីយ៍ឯក ម៉ាណែត បានមានប្រសាសន៍ថា លោកជឿថាបុរសរងរបួសគឺលោក ផូល ហេ "បានជំពប់ជើងហើយដួល" ហើយថាអង្គរក្សរបស់លោកនឹងត្រូវចាប់ខ្លួន ប្រសិនបើបុរសជនជាតិអាមេរិកាំងនោះត្រូវបានគេវាយមែននោះ។

លោក ហេ ជាអ្នកស៊ើបអង្កេតឯកជនបានប៉ុនប៉ងប្រគល់ដីកានៃរឿងក្តីសហព័ន្ធសហរដ្ឋអាមេរិកឱ្យឧត្តមសេនីយ៍ឯក ម៉ាណែត នៅថ្ងៃទី៩ ខែមេសា នៅខាងក្រៅភោជនីយដ្ឋានមួយនៅពេលនោះលោកអះអាងថា មានអង្គរក្សម្នាក់បានចាប់លើករូបលោក ហើយក៏បោះទៅលើដីក្បាលទៅមុនដោយធ្វើឱ្យខូចឆ្អឹងខ្នងរបស់លោក។

លោក ប្រេដ ចនសុន អ្នកនាំពាក្យនគរបាលក្រុងឡុងប៊ិចបាននិយាយក្នុងសារអ៊ីម៉េលកាលពីថ្ងៃសៅរ៍ថា "ខ្ញុំអាចបញ្ជាក់បានថា ករណីនេះកំពុងត្រូវគេស៊ើបអង្កេត ហើយចាត់ឱ្យមានអ្នកស៊ើបអង្កេតម្នាក់ធ្វើការក្នុងរបាយការណ៍លម្អិតនៃបទល្មើសហិង្សារបស់យើង"។

លោក ចនសុន បានមានប្រសាសន៍បន្តថា មិនមានការចាប់ខ្លួនទេ ប៉ុន្តែថា នគរបាលមានវត្តមាននៅពេលដែលលោក ហេ ត្រូវគេវាយដំដោយសារតែមានការតវ៉ាប្រឆាំងដំណើរទស្សនកិច្ចមកកាន់សហរដ្ឋអាមេរិកនាពេលចូលឆ្នាំខ្មែររបស់ឧត្តមសេនីយ៍ឯក ម៉ាណែត។

អ្នកនាំពាក្យរូបនេះបាននិយាយថា "នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៦ នៅម៉ោង៥ និង២២នាទីល្ងាច មន្ត្រីនគរបាលបានត្រៀមខ្លួន ដើម្បីជួយរក្សាភាពស្ងប់ស្ងាត់ក្នុងពេលមានការតវ៉ាតាមវិថីអាត់ឡង់ទិកលេខ១៤00 នៅពេលនោះ ពួកគេក៏ត្រូវទាក់ទងដោយជនរងគ្រោះពីការវាយដំ"។

លោកបាននិយាយបន្ថែមថា "ជនរងគ្រោះឱ្យលោក ហេ បានប្រាប់ពួកគេថា លោកគឺជាអ្នកស៊ើបអង្កេតឯកជន ហើយមានបំណងប្រគល់ដីកាឱ្យ ហ៊ុន ម៉ាណែត នាយរងសេនាធិការនៃកងយោធពលខេមរភូមិន្ទ"។

លោកបាននិយាយថា "នៅពេលដែលលោកប៉ុនប៉ងប្រគល់ដីកា សរាប់តែលោកក៏ត្រូវបានរុញឱ្យដួលទៅលើដីដោយជនសង្ស័យមិនស្គាល់ឈ្មោះ ហើយក៏ប៉ះចំក្បាលរបស់លោក។ ការស៊ើបអង្កេតកំពុងតែបន្ត"។

លោក ហេ ដែលបានទទួលការសង្គ្រោះបន្ទាន់កាលពីសប្តាហ៍មុន ហើយករបស់លោកនៅរុំអបនៅឡើយ បានមានប្រសាសន៍កាលពីថ្ងៃអាទិត្យថា លោកសប្បាយចិត្តណាស់ដែលនគរបាលបានកំពុងស៊ើបអង្កេតករណីនេះ ប៉ុន្តែលោកបានដឹងតិចតួចអំពីរឿងនេះ។

លោក ហេ បានមានប្រសាសន៍ថា "នៅពេលដែលប្រពន្ធរបស់ខ្ញុំយកខ្ញុំចេញពីមន្ទីរពេទ្យមកផ្ទះស្រាប់តែនគរបាលស្កាត់មកជួបយើង ហើយបន្ទាប់មកខ្ញុំក៏ទទួលបានការហៅទូរស័ព្ទពីអ្នកអង្កេតម្នាក់ដែលនៅឯមន្ទីរពេទ្យកំពុងរកជួបខ្ញុំ។ នោះជារឿងដែលខ្ញុំបានដឹង"។

ឧត្តមសេនីយ៍ឯក ម៉ាណែត មិនបានឆ្លើយតបនឹងសំណើសុំអត្ថាធិប្បាយច្រើនលើកច្រើនសាទាក់ទងនឹងលោក ហេ ឬរឿងក្តីនោះទេ។

ទោះជាយ៉ាងនេះក្តី ក្នុងបទសម្ភាសមួយជាមួយក្រុមប្រឹក្សានិពន្ធនៃកាសែត ឡូវែល សាន់ នៅក្នុងរដ្ឋម៉ាស្សាជូសិតកាលពីថ្ងៃសៅរ៍ឧត្តមសេនីយ៍ឯក ម៉ាណែត ត្រូវបានសួរអំពីដីកានោះដែលត្រូវយកមកប្រគល់ជូនដោយលោក ហេ។

ឧត្តមសេនីយ៍ឯក ម៉ាណែត បានមានប្រសាសន៍មុននឹងបដិសេធថា អង្គរក្សរបស់លោកមិនបានវាយដំលោក ហេ ថា **តទៅទំព័រទី ២១**

# CASE OPENED INTO CLAIMS OF ASSAULT BY MANET'S GUARD

**by Alex Willemyns | April 18, 2016 |**

Police in Long Beach, California, said on Saturday that they had opened an investigation into the alleged assault of an American man by a bodyguard of Prime Minister Hun Sen's son Hun Manet.

Yet Lieutenant General Manet, in an interview on the same day, said that he believed the injured man, Paul Hayes, had "somehow tripped and fell" and that his bodyguards would have been arrested had he been assaulted.



Paul Hayes lies on the ground on April 9 in a parking lot in Long Beach, California, where he claims he was assaulted by a bodyguard for Hun Manet, in a photograph posted to the Cambodia-America Alliance Facebook page.

Mr. Hayes, a private investigator, was attempting to serve a subpoena for a U.S. federal lawsuit to Lt. Gen. Manet on April 9 outside a restaurant when, he claims, a bodyguard lifted him and threw him to the ground head-first, damaging his spine.

"I can confirm that the case is being investigated and is assigned to a Detective in our Violent Crimes Detail," Brad Johnson, a spokesman for the Long Beach police department, said in an email Saturday. "That detective will be back to work on Monday."

Mr. Johnson added that no arrests had been made but that police were present when Mr. Hayes was allegedly assaulted, due to a protest being held against Lt. Gen. Manet's Khmer New Year trip to the U.S.

"On 4/9/16 at 5:22 p.m., officers were on standby to assist with keeping the peace during a protest in the 1400 block of Atlantic Avenue when they were contacted by a victim of a battery," he said.

"The victim [Mr. Hayes] advised them he was a private investigator and was attempting to serve a subpoena to Hun Manet, Deputy Chief of Staff of the Royal Cambodian Armed Forces," he added.

"When he attempted to serve the subject he was pushed to the ground by unknown suspects and struck his head," he said. "Investigation remains ongoing."

Mr. Hayes, who spent much of last week in intensive care and remains in a neck brace, said on Sunday that he was pleased that police were investigating the case but knew little more about it.

"When my wife brought me home from the hospital on Thursday, we stopped by the police department and then I got a call from a detective who was at the hospital looking for me. That's all I've heard," Mr. Hayes said.

Lt. Gen. Manet has not responded to multiple requests for comment about Mr. Hayes or the lawsuit.

However, in an interview with the editorial board of the Lowell Sun newspaper in Massachusetts on Saturday, Lt. Gen. Manet was asked about the subpoena that was being delivered by Mr. Hayes.

"The day I arrived, I didn't even know until I saw it on social media the next day from Cambodia, people saying that you are being sued for this and that," Lt. Gen. Manet said, before denying that his bodyguards assaulted Mr. Hayes. **Continued to Page 27**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# តំណាងរាស្ត្រគណបក្សប្រឆាំងត្រូវបានចាប់ខ្លួនខណៈអភ័យឯកសិទ្ធិរងការវាយប្រហារធ្ងន់ធ្ងរ

**ដោយ អួន ភាព និងអេឡិក វិល្លឹមមីនស៍ |**
**April 12, 2016**

នគរបាលបានចាប់ខ្លួនលោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សប្រឆាំងកាលពីរំលងអាធ្រាត្រឈានចូលព្រឹកម្សិលមិញនៅក្រុងសៀមរាបទាក់ទិនការតស៊ូមតិរបស់លោកប្រឆាំងការទន្ទ្រានចូលព្រំដែនពីសំណាក់វៀតណាម ហើយនេះឆ្លុះបញ្ចាំងពីការបំផ្លាញការការពារដោយរដ្ឋធម្មនុញ្ញដែលហាមប្រាមការចាប់ខ្លួនតំណាងរាស្ត្រដោយគ្មានការយល់ព្រមពីរដ្ឋសភា។

លោក អ៊ុំ សំអាន ដែលជាអ្នកផ្ដើមគំនិតមួយរូបនៃយុទ្ធនាការមួយរបស់គណបក្សសង្គ្រោះជាតិកាលពីឆ្នាំមុន?ដើម្បីធ្វើឱ្យរដ្ឋាភិបាលអាម៉ាស់មុខចំពោះការបណ្ដែតបណ្ដោយឱ្យជនស៊ីវិល និងទាហានវៀតណាមអះអាងសិទ្ធិកាន់កាប់អធិបតេយ្យរបស់កម្ពុជា តាមតែអំពើចិត្តនោះត្រូវបានចាប់ខ្លួនប៉ុន្មានម៉ោងបន្ទាប់ពីវិលត្រឡប់ពីការនិរទេសខ្លួននៅសហរដ្ឋអាមេរិក និងអឺរ៉ុប។

ក្រោមការបកស្រាយដ៏ទូលំទូលាយនៃមាត្រាមួយក្នុងរដ្ឋធម្មនុញ្ញដែលអនុញ្ញាតឱ្យចាប់ខ្លួនតំណាងរាស្ត្រនៅពេលកំពុងប្រព្រឹត្តបទល្មើសដែលគេហៅថា "បទល្មើសជាក់ស្ដែង" លោកត្រូវបានចាប់ខ្លួនពាក់ព័ន្ធសារបង្ហោះតាមហ្វេសប៊ុកដែលលោកសរសេរកាលពីឆ្នាំមុន នេះបើយោងតាមការលើកឡើងរបស់លោកជិនម៉ាលីនអ្នកនាំពាក្យក្រសួងយុត្តិធម៌។

អ្នកនាំពាក្យរូបនេះមានប្រសាសន៍តាមទូរស័ព្ទកាលពីម្សិលមិញថា "យើងចាប់ខ្លួនគាត់ពីបទរើសអើងការប្រើប្រាស់ផែនទីក្លែងក្លាយនិងបទញុះញង់ដែលបង្កអសន្តិសុខក្នុងសង្គម។ នគរបាលមើលឃើញថា ទាំងនេះជាបទល្មើស ដូច្នេះហើយគេក៏ចាប់ខ្លួនគាត់យកទៅសាកសួរ។ គេនឹងបញ្ជូនសំណុំរឿងនេះទៅតុលាការហើយព្រះរាជអាជ្ញានឹងចោទប្រកាន់គាត់យោងទៅលើបទល្មើសទាំងនេះ"។

លោកបានបន្ថែមថា លោក អ៊ុំ សំអាន កំពុងជាប់ឃុំនៅក្រសួងមហាផ្ទៃ។ "គាត់នឹងត្រូវបញ្ជូនខ្លួនទៅតុលាការនៅថ្ងៃស្អែក"។

ទោះជាយ៉ាងណា កាលពីរសៀលម្សិលមិញ លោក អ៊ុំ សំអាន ក៏ត្រូវបានបញ្ជូនខ្លួនពីក្រសួងទៅសាលាដំបូងរាជធានីផងដែរដើម្បីធ្វើការសាកសួរ ហើយបានឆ្លៀតឱកាសនេះដើម្បីអំពាវនាវទៅដល់អ្នកកាសែត។ លោកថ្លែងថា "នេះជារឿងក្ដីអយុត្តិធម៌។ ខ្ញុំត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបង្កចលាចលក្នុងសង្គម"។

លោក ជិន ម៉ាលីនមានប្រសាសន៍ថា សារបង្កហេតុដែលលោក អ៊ុំ សំអាន បានបង្ហោះជាសាធារណៈតាមហ្វេសប៊ុកពីសហរដ្ឋអាមេរិកកាលពីឆ្នាំមុន ដែលបានចោទប្រកាន់ថា គណបក្សប្រជាជនកម្ពុជាថាឃុបឃិតឱ្យវៀតណាមចូលលុកលុយកម្ពុជាចូលលុកលុយកម្ពុជា និងដែលត្រូវបានប្រព័ន្ធផ្សព្វផ្សាយចុះផ្សាយព្រោងព្រាតបានធ្វើឱ្យករណីរបស់គាត់ក្លាយជាបទល្មើសជាក់ស្ដែង។

លោកបានគូសបញ្ជាក់ថា "ខ្ញុំផ្ដល់ឧទាហរណ៍មួយថា បើលោក អ៊ុំ សំអាន សម្លាប់មនុស្សម្នាក់ហើយរត់គេចខ្លួន?ប៉ុន្តែក្រោយមកត្រឡប់មកវិញនគរបាលអាចចាប់ខ្លួនគាត់បានដោយសារតែគាត់បានប្រព្រឹត្តបទល្មើសជាក់ស្ដែងហើយគេគ្រប់គ្នាដឹងថា គាត់បានធ្វើវាពីមុន។ អ្វីដែលគាត់បានធ្វើកាលពីឆ្នាំ២០១៥ គឺចាត់ទុកជាបទល្មើសជាក់ស្ដែង។ ទោះបីជាវាកើតឡើងកន្លងហួសទៅហើយក្ដី វាក៏នៅតែចាត់ទុកជាបទល្មើសជាក់ស្ដែងដដែលបើគិតពីទិដ្ឋភាពផ្លូវច្បាប់និងបច្ចេកទេស"។

គេមិនច្បាស់ថា តើសារជាច្រើនដែលលោកអ៊ុំសំអាន បានបង្ហោះតាមហ្វេសប៊ុកបានបំពានច្បាប់ឬយ៉ាងណាទេ?ប៉ុន្តែកាលពីឆ្នាំមុនតំណាងរាស្ត្ររូបនេះបានបន្តចោទប្រកាន់គណបក្សប្រជាជនកម្ពុជា ថាប្រើប្រាស់ផែនទីព្រំដែនក្លែងក្លាយក្រោយថ្ងៃទី២១ខែសីហាជាពេលដែលលោកនាយករដ្ឋមន្ត្រីហ៊ុនសែនព្រមានថា ការអះអាង

**តទៅទំព័រទី ១៨**



លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិត្រូវសមត្ថកិច្ចចាប់ក្រៀកចេញពីក្រសួងមហាផ្ទៃកាលពីម្សិលមិញ បន្ទាប់ពីត្រូវឃាត់ខ្លួននៅក្រុងសៀមរាប នៅពេលរំលងអធ្រាត្រ។ រូបថត: ThmeyThmey

# IN BLOW FOR IMMUNITY, LAWMAKER ARRESTED

**by AunPheap and Alex Willemyns**
**| April 12, 2016**

Demolishing the constitutional protection forbidding the arrest of lawmakers without National Assembly consent, police apprehended opposition lawmaker Um Sam An early Monday morning in Siem Reap City over his advocacy against Vietnamese border intrusions.

One of the architects of a CNRP campaign last year to embarrass the government for allowing Vietnamese civilians and soldiers to arbitrarily claim sovereign Cambodian territory, Mr. Sam An was arrested hours after returning from exile in the U.S. and Europe.

Under a very broad interpretation of a clause in the Constitution permitting lawmakers' arrests when they are caught in the act of a crime-referred to by the Latin phrase "in flagrante delicto"-he was seized over Facebook posts written last year, said Justice Ministry spokesman Chin Malin.

"We arrested him for discrimination, using fake maps and incitement causing insecurity in society," Mr. Malin said by telephone on Monday. "Police see that these are crimes, so they arrested him for questioning."

"They will send this case to court, and the prosecutor will charge him according to these crimes," Mr. Malin said, adding that Mr. Sam An was being detained at the Interior Ministry. "He will be sent to court tomorrow."

On Monday afternoon, however, Mr. Sam An was also transferred briefly from the ministry to the municipal court for questioning, and used the opportunity to call out to reporters.

"This is an unjust case. I have been accused of incitement and causing turmoil in society," he said.

Mr. Malin, the spokesman, said Mr. Sam An's provocative and public Facebook posts from the U.S. last year, which accused the CPP of complicity in Vietnamese incursions into Cambodia and were widely covered by the media, rendered his case "in flagrante delicto."

"I give, as an example, that if Mr. Um Sam An killed someone and escaped but then returned, the police could arrest him because he committed an obvious crime, and everyone knows he did it before," Mr. Malin said.

"What he did in 2015 is considered as flagrante delicto. Even if it happened in the past, it's still considered flagrante delicto from a legal and technical perspective."

It is not clear which of Mr. Sam An's many Facebook posts violated the law, but the lawmaker last year continued to accuse the CPP of using fake border maps long after August 21, when Prime Minister Hun Sen warned that such claims would lead to arrest.

The lawmaker also often posted what he said were the correct French colonial maps of Cambodia's eastern border with Vietnam, which the Constitution dictates are the only ones that can be used for border demarcation.

"I say the government's maps are illegal because those maps differ from the maps stipulated in Article 2 of the Constitution," Mr. Sam An wrote in September, calling Mr. Hun Sen's maps of the Cambodian-Vietnamese border an "inheritance left by the Yuon in the 1980s."

"Yuon" is a word for the Vietnamese considered pejorative by many but often used by the opposition, which has long sought to take advantage of the fact that Vietnam installed Mr. Hun Sen and his government in power during its 1979 to 1989 military occupation of Cambodia.

Monday's arrest, which was carried out months after Mr. Sam An's alleged crime-and while he was withdrawing money from an ATM, according to deputy Siem Reap provincial police chief Huot Sothy-now raises questions about the future of the legal immunity granted to lawmakers.

The privilege is provided to all elected lawmakers by Article 80 of the Constitution, which reads: "The accusation, arrest, or detention of an assembly member shall be made only with the permission of the National Assembly…except in case of flagrante delicto."

**Continued to Page 23**

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# ការដាក់ពន្ធនាគារតំណាងរាស្ត្របក្សប្រឆាំងពីបទល្មើស ព្រហ្មទណ្ឌជាក់ស្តែងបំពានរដ្ឋធម្មនុញ្ញ

**ដោយ អេឡិក វិល្លឹមមីនស៍និងអួន ភាព ।**

**April 18, 2016**

មុនពេលចាកចេញពីប្រទេសកម្ពុជាកាលពីខែមុន លោកស្រី រ៉ូណា ស្មីត អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា បានសម្តែងការជំទាស់ទៅនឹងអ្វីដែលលោកស្រីលើកឡើងថាជាការកើតមានជាទូទៅនៃករណីដែលមាន "ភាពខុសគ្នារវាងអ្វីដែលច្បាប់បានចែងនិងការអនុវត្តនៅពេលនោះ" ។

ចាប់តាំងពីលោកស្រីបានចាកចេញទៅ ភាពខុសគ្នានេះកាន់តែមានការគួរឱ្យកត់សម្គាល់ជាងនៅក្នុងការបកស្រាយទាំងស្រុងរបស់រដ្ឋាភិបាលនូវមាត្រាក្នុងរដ្ឋធម្មនុញ្ញដែលហាមមិនឱ្យចាប់ខ្លួនសមាជិកសភាដោយគ្មានការឯកភាពពីសំឡេង២ភាគ៣នៃរដ្ឋសភា ។

ការចាប់លោក អ៊ុំ សំអាន តំណាងរាស្ត្រគណបក្សប្រឆាំងដាក់ពន្ធនាគារកាលពីសប្តាហ៍មុនដោយសារការបង្ហោះសារតាមបណ្តាញទំនាក់ទំនងសង្គមកាលពីឆ្នាំមុននោះ រដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាដែលគ្មានអាសនៈ២ភាគ៣នៅក្នុងរដ្ឋសភាបានលើកឡើងថា សំឡេងភាគច្រើនបែបនេះមិនចាំបាច់ទេ ព្រោះមានការលើកលែងដែលអនុញ្ញាតឱ្យមានការចាប់ខ្លួនប្រសិនបើសមាជិកសភាត្រូវបានរកឃើញថា បានប្រព្រឹត្តបទល្មើសជាក់ស្តែង ។

ការអះអាងបែបនេះផ្អែកលើវាក្យខណ្ឌនៅក្នុងមាត្រា៨០នៃរដ្ឋធម្មនុញ្ញដែលផ្តល់អភ័យឯកសិទ្ធិដល់សមាជិកសភារួចផុតពីការចាប់ខ្លួន ប៉ុន្តែមានករណីលើកលែង "នៅក្នុងករណីណាមានបទល្មើសជាក់ស្តែង" គឺពេលដែលគេចាប់បានសមាជិកសភាកំពុងប្រព្រឹត្តបទល្មើស ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ពេលថ្លែងសុន្ទរកថាកាលពីថ្ងៃអង្គារថា "កុំនិយាយថា លោកឯងមានអភ័យឯកសិទ្ធិ ហើយគេមិនអាចចាប់ខ្លួនលោកឯងបាននោះ ព្រោះវាជាបទល្មើសជាក់ស្តែង" ។ លោកបានពន្យល់ថា បទល្មើសរបស់លោក អ៊ុំ សំអាន អ្នកទាំងអស់គ្នាអាចនៅមើលឃើញនៅឡើយ ។ លោកបានមានប្រសាសន៍បន្ថែមថា "ពេលនេះម៉ោងនេះទំព័ររបស់លោកឯងនៅតែនិយាយអំពីផែនទីក្លែងក្លាយនៅឡើយទេ" ។ ខ្ញុំមិនខ្វល់ថា លោកឯងជាសមាជិកសភា ឬសមាជិកព្រឹទ្ធសភានោះឡើយ" ។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិរូបនេះត្រូវបានចោទប្រកាន់តាមការគ្រោងទុកនៅប៉ុន្មានម៉ោងក្រោយមកពីបទញុះញង់កាលពីថ្ងៃទី៩ ខែមេសា ។ លោកត្រូវបានចាប់ខ្លួនមិនយូរប៉ុន្មានក្រោយពេលរំលងអធ្រាត្រឈានចូលថ្ងៃទី១០ ខែមេសា ទោះបីជាលោកបានធ្វើការបង្ហោះសារទាក់ទិនការកំណត់ព្រំដែនប្រហែល៦ខែកន្លងមកហើយក៏ដោយ ។

លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធមិបានលើកឡើងកាលពីសប្តាហ៍មុនថា "ទោះបីជាវាកើតឡើងកន្លងហួសទៅហើយក្តី វាក៏នៅតែចាត់ទុកជាបទល្មើសជាក់ស្តែងដដែល បើគិតពីទិដ្ឋភាពផ្លូវច្បាប់ និងបច្ចេកទេស" ។

លោកបានបន្ថែមថា "ខ្ញុំផ្តល់ឧទាហរណ៍មួយថា **តទៅទំព័រទី ២៣**

# OPPOSITION LAWMAKER UM SAM AN ARRESTED

**by AunPheap and Alex Willemyns**

**| April 11, 2016**

Opposition lawmaker Um Sam An was arrested at about midnight on Sunday in Siem Reap province for a crime related to his advocacy against Vietnamese border encroachments last year, Interior Ministry spokesman KhieuSopheak said Monday





CNRP lawmaker Um Sam An is detained at the Interior Ministry's department of anti-terrorism and cross-border crimes on Monday morning. (Fresh News)

morning.

Taking a liberal interpretation of the "in flagrante delicto" exception to a lawmaker's constitutional immunity from arrest and prosecution, which allows for arrest when a lawmaker is caught red-handed, police arrested Mr. Sam An after his return from an extended stay overseas.

"Police arrested Um Sam An last night in Siem Reap," General Sopheak said, explaining that the arrest was similar to that of opposition Senator Hong Sok Hour, who was also arrested despite his parliamentary immunity.

"The case of Um Sam An not different from the case of Hong Sok Hour, because he criticized the government about selling land to Vietnam and he also criticized the government for using fake maps," he said.

It is not yet clear exactly what crime Mr. Sam An stands accused of committing.

Mr. Sok Hour was arrested in August last year on the order of Prime Minister Hun Sen after he used a fake diplomatic border treaty between Vietnam and Cambodia during a lecture-posted in a video to Facebook-at the height of the CNRP's campaign against alleged Vietnamese border encroachments.

He remains in jail, in spite of his parliamentary immunity, with the CPP-dominated Senate having met and decided it did not have to strip his immunity because the video counted as "in flagrante delicto."

Mr. Sam An himself was at the fore of that border campaign, often accusing the government of using Vietnamese-drawn border maps, even after Mr. Hun Sen said he would arrest anybody who leveled such accusations against the government.

Local media reported on Monday morning that Mr. Sam An was now being questioned by anti-terrorism police at the Ministry of Interior in Phnom Penh but Gen. Sopheak said that he could not confirm the reports.

"I do not know where Um Sam An was detained. I wish to hide this information," Gen. Sopheak said.

CNRP spokesman Yim Sovann said Mr. Sam An was still entitled to his immunity, as the National Assembly had not voted with a two-thirds majority to strip him of it. Neither party holds such a supermajority in parliament.

"It's against the Constitution. Um Sam An is still a member of parliament, he has immunity and he yet was arrested last night in Siem Reap," Mr. Sovann said, rejecting the idea that he was caught "in flagrante delicto."

"This was a long time ago, and no one was talking about that. Before the arrival of Um Sam An, there was no information about that. He arrived in Cambodia, and then there was information," he added.

Yet Justice Ministry spokesman Chin Malin said the arrest was legal given the "in flagrante delicto" exception to a lawmaker's immunity from prosecution.

"This case is legal because according to the crimes of 'in flagrante delicto,' we do not need to remove any immunity," he said.

But Mr. Malin said he could not yet specify exactly what crime Mr. Sam An had been caught doing.

"I cannot give further comment," he said. "We are currently filing some documents and I can explain later."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស    អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ជួនកាលគេដុតភូមិទាំងមូល

**ដោយឌឹ ខេមបូឌា ដេលី** | April 13, 2016

***ដោយរំលោភយ៉ាងជាក់ស្តែងលើច្បាប់ស្តីពីសិទ្ធិមនុស្សសហរដ្ឋអាមេរិកផ្តល់ការបណ្តុះបណ្តាល***



នគរបាលនិងកងរាជអាវុធហត្ថឈរយាម អ្នកភូមិស្ពានជេស ក្នុងខេត្តព្រះសីហនុ បន្ទាប់ពីដុតផ្ទះពួកគេឱ្យឆេះនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៧។ រូបថតដោយ អង្គការលីកាដូ

***ផល់អ្នកជាប់ចោទថារំលោភសិទ្ធិមនុស្សនៅកម្ពុជា***

**ដោយ** Douglas Gillison 100reporters

ខេត្តព្រះសីហនុ-វាជារូបភាពហិង្សាដោយដុតភ្លើងដែលកើតចេញពីទំនាស់ដីធ្លីដែលបានកើតឡើងទូទាំងប្រទេសកម្ពុជាអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមក។ ក្រោមកម្តៅថ្ងៃក្តៅថែសហួតហែងនាវដូវប្រាំងយោធាបានបាញ់សំដៅអ្នកភូមិ និងដុតផ្ទះសំបែងរបស់ពួកគេនៅក្នុងខេត្តជាប់មាត់សមុទ្រមួយនេះ។

សាក្សីទាំងឡាយបាននិយាយថា ការបណ្តេញចេញពីដីធ្លីមួយក្នុងខែមេសា ឆ្នាំ២០០៧ នៅក្នុងភូមិមួយដែលមានឈ្មោះថា ស្ពានជេស គឺឃោរឃៅណាស់។ កម្លាំងសន្តិសុខបានបាញ់ក្នុងចម្ងាយជិត១ដោយបង្កជារបួសស្នាមប្រើគ្រាប់ពិត ដើម្បីបំបែកហ្វូងមនុស្ស និងវាយតប់អ្នកភូមិដែលជួនកាលដោយប្រើដំបងឆក់។

កម្លាំងចម្រុះដែលមានសមាជិកប្រហែល១៥០នាក់មកពីក្រុមនគរបាល កងទ័ព កងរាជអាវុធហត្ថ បានដុតផ្ទះចំនួន៨០ខ្នង ហើយកម្ទេចចោល២៦ខ្នងផ្សេងទៀត។

លោក យ៉ាង រ៉េន អាយុ៣២ឆ្នាំ បាននិយាយថា "គេប្រើកាំភ្លើងបាញ់មួយប្រភេទបាញ់ចេញភ្លើងដើម្បីដុតកម្ទេចផ្ទះសំបែង"។

លោក រ៉េន បាននិយាយថា កងរាជអាវុធហត្ថបានចាប់ខ្លួនអ្នកភូមិ ច្រានពួកគេឱ្យដេកផ្កាប់មុខ ហើយធាក់ច្រំចំក្បាលពួកគេ។ "យើងតក់ស្លុតពន់ពេក នៅពេលយើងឮថា ផ្ទះយើងត្រូវគេកម្ទេចចោលដោយម៉ាស៊ីនចូកដី"។

នៅខែនោះ កងនាវាជើងទឹកមួយកងបានសម្រុកចូលសហគមន៍មួយទៀតចម្ងាយប្រហែល២០គីឡូម៉ែត្រពីទីនោះ ដោយវាយអ្នកភូមិម្នាក់ឱ្យសន្លប់ដេកស្តូកស្តឹង ហើយដុតបំផ្លាញផ្ទះប្រាំខ្នងដើម្បីដណ្តើមយកដីធ្លីដែលអ្នកភូមិឥឡូវនេះ និយាយថា គឺជាផ្នែកនៃទីលានសម្រាប់សាលាបណ្តុះបណ្តាលទ័ពជើងទឹក។

ក្នុងខណៈដែលតម្លៃអចលនទ្រព្យហក់ឡើងកាលពីមួយទសវត្សរ៍កន្លងមកនេះ សហគមន៍តំបន់ជនបទនិងទីក្រុងដែលក្រីក្ររបស់ប្រទេសនេះបានជាប់ផុងខ្លួនក្នុងសមរភូមិដីធ្លីជាមួយនឹងពួកអ្នកមានអំណាចដែលមានសិទ្ធិទាមទារអចលនទ្រព្យដ៏មានតម្លៃ។ យោងតាមអង្គការលីកាដូឱ្យដឹងថា នៅឆ្នាំ២០១៤មានពលរដ្ឋជាងកន្លះលាននាក់ទទួលរងផលប៉ះពាល់ដោយការបណ្តេញចេញពីដីធ្លី។

ទំហំនិងការបណ្តេញចេញដោយហិង្សានៅឯភូមិស្ពានជេសបានក្លាយជានិមិត្តរូបយ៉ាងឆាប់រហ័សនៃវិបត្តិនេះ ដោយទាក់ទាញការចាប់អារម្មណ៍ពីសំណាក់ស្ថានទូតសហរដ្ឋអាមេរិកនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០០៧របស់ខ្លួនស្តីពីសិទ្ធិមនុស្ស។ នៅក្នុងឆ្នាំ២០១៤ ការបណ្តេញចេញពីភូមិស្ពានជេសបានជួយបង្កើតឱ្យមានមូលដ្ឋាននៃវិធានការផ្លូវច្បាប់ជាឯកជនដែលចោទប្រកាន់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវប្តឹងទៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។

ប៉ុន្តែក្នុងពេលដែលវិបត្តិនោះបានលាតត្រដាងក៏ស្រាប់តែរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនបានបង្កើនទំនាក់ទំនងរបស់ខ្លួនជាមួយកងយោធពលខេមរភូមិន្ទនិងនគរបាល។

ក្នុងឆ្នាំ១៩៩៧ សភាអាមេរិកបានចាត់ទុកថា ខុសច្បាប់នូវជំនួយចំពោះកងកម្លាំងសន្តិសុខបរទេសដែលគេដឹងថា បានរំលោភសិទ្ធិមនុស្សទាំងស្រុង ។ ប៉ុន្តែឯកសារការទូតដែលចេញផ្សាយដោយវីគីលីក ហើយចងក្រងដោយក្រុមវិជ្ជាជីវៈសារព័ត៌មានស៊ើបអង្កេតដែលមិនរកផលកម្រៃឈ្មោះថា ១00Reporters បង្ហាញថា មន្ត្រីអាមេរិកាំងបានមើលរំលងការរំលោភសិទ្ធិមនុស្សបែបហ្នឹង ដោយជ្រើសរើសនគរបាល និងយោធាកម្ពុជាឱ្យមានសិទ្ធិទទួលបានការបណ្តុះបណ្តាលដែលផ្តល់មូលនិធិដោយសហរដ្ឋអាមេរិក ពោលគឺក្នុងករណីខ្លះមានការរំលោភច្បាប់តែម្តង។

រយៈពេលពីរឆ្នាំបន្ទាប់ពីមានអំពើហិង្សានៅឯភូមិស្ពានជេស ស្ថានទូតសហរដ្ឋអាមេរិកប្រចាំក្រុងភ្នំពេញបានឱ្យសេចក្តីយល់ព្រមជ្រើសរើសលោកវរសេនីយ៍ឯក សេង ភោគ មេបញ្ជាការរងកងរាជអាវុធហត្ថឱ្យទទួលបានការបណ្តុះបណ្តាលពីសហរដ្ឋអាមេរិក ដែលរូបលោកត្រូវបុគ្គលិកសិទ្ធិមនុស្សម្នាក់និយាយថា បានស្ថិតក្នុងបណ្តាមេបញ្ជាការដែលឈរបញ្ជាពេលមានការបណ្តេញចេញពីដីធ្លីនោះ។

១០០ព្រេវរតរេស ក៏បានរកឃើញថាសហរដ្ឋអាមេរិកបានផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកទេសស៊ើបអង្កេតដល់សមាជិកជាន់ខ្ពស់នៃស្នងការដ្ឋាននគរបាលជាតិកម្ពុជានៅពេលនោះ គឺជាប្រធានបទនៃការចោទប្រកាន់ថា មានឃាតកម្មនិងការចាប់ជម្រិតជាហូរហែ។

ការចោទប្រកាន់ទាំងនោះមានកត់ត្រាទុកក្នុងកំណត់ហេតុតុលាការនិងឯកសារអង្គការសហប្រជាជាតិដែលនឹងអាចរកបានយ៉ាងងាយដោយស្ថានទូតសហរដ្ឋអាមេរិកដែលបានបញ្ជូនឈ្មោះរបស់ពួកគេទៅក្រុងវ៉ាស៊ីនតោនដើម្បីសុំការយល់ព្រម។

នៅក្នុងការស៊ើបអង្កេតមួយដែលបណ្តាលមកពីទិន្នន័យនេះដោយបានធ្វើឡើងអស់រយៈពេលជាងមួយឆ្នាំដោយប្រើបណ្តុំកំណត់ហេតុផ្នែកការទូតអាមេរិកាំងនោះ **តទៅទំព័រទី ១៧**



មន្ត្រីកងរាជអាវុធហត្ថ (ស្តាំ) យារជើងនឹងទាត់អ្នកភូមិម្នាក់។ រូបថតដោយ អង្គកាលីកាដូ



A man stands outside his shack in the village of Spean Ches.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# តមកពីទំព័រទី ១៦ ជួនកាលគេដុតភូមិទាំងមូល

១00Reportersបានពង្រីកទិន្នន័យតម្រង់ទិសលើបុគ្គលប្រហែល៦០.០០០នាក់ពីប្រទេសចំនួន១២៥ដែលជ្រើសរើសសម្រាប់ហ្វឹកហាត់ដោយទីភ្នាក់ងារសហព័ន្ធសហរដ្ឋអាមេរិកប្រហែល១៤០ទីភ្នាក់ងារ។

ជនសង្ស័យរត់ពន្ធគ្រឿងញៀន ឃាតករ អ្នកធ្វើទារុណកម្ម និងអង្គភាពបរទេសដែលជាប់ពាក់ព័ន្ធនឹងការសម្លាប់ក្រៅច្បាប់ជាលក្ខណៈប្រព័ន្ធ គឺត្រូវបានរកឃើញនៅក្នុងមូលដ្ឋានទិន្នន័យ។ ពួកគេភាគច្រើនអាចឆ្លងផុតការពិនិត្យរបស់អាមេរិកាំង ហើយទទួលបានការបណ្តុះបណ្តាល។

លោក នី ចរិយា ប្រធានស៊ើបអង្កេតនៅសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍កម្ពុជា (Gadhuk) ដែលផ្តល់មូលនិធិដោយសហរដ្ឋអាមេរិក ដែលចាប់ផ្តើមជួយស្ថានទូតសហរដ្ឋអាមេរិកក្នុងការពិនិត្យជ្រើសរើសមន្ត្រីកម្ពុជាបួនប្រាំឆ្នាំមុន បានមានប្រសាសន៍ថា លោកព្រួយបារម្ភចំពោះការខកខានមិនបានដកចេញនូវបេក្ខជនគួរឱ្យសង្ស័យ។ លោកបាននិយាយថា "នៅពេលអ្នកឃើញថា មនុស្សម្នាក់ដែលរំលោភសិទ្ធិមនុស្សទទួលបានការបណ្តុះបណ្តាល គឺវាហាក់ដូចជាគេទទួលបានការលើកទឹកចិត្តអ៊ីចឹង ហើយនេះមិនមែនជារឿងល្អទេ។ វាបណ្តាលឱ្យគេកាន់តែរំលោភសិទ្ធិមនុស្ស"។

នៅពេលមានការបណ្តេញចេញពីដីធ្លីកាលពីឆ្នាំ២០០៧នៅខេត្តជាប់ឆ្នេរសមុទ្រនេះ មន្ត្រីសហរដ្ឋអាមេរិកបានសង្ស័យថា ការពិនិត្យដោយផ្ចិតផ្ចង់ផ្នែកសិទ្ធិមនុស្សទៅលើកងកម្លាំងសន្តិសុខក្នុងស្រុក គឺមានបញ្ហា។ ក្នុងខែមករា ឆ្នាំនោះ មានមន្ត្រីមួយក្រុមពីការិយាល័យអគ្គអធិការក្រសួងការបរទេសសហរដ្ឋអាមេរិកបានមកស្ថានទូតក្នុងក្រុងភ្នំពេញ ហើយបន្ទាប់មកបានរាយការណ៍ថា ដំណើរការពិនិត្យជ្រើសរើស គឺ "ប្រញាប់ប្រញាល់ ហើយមិនស្មើគ្នា"។

ក្នុងការអនុវត្ត ការតម្រូវឱ្យជ្រើសរើសដោយផ្ចិតផ្ចង់របស់សភាសហរដ្ឋអាមេរិក ដែលមានឈ្មោះថា ច្បាប់ស្តីពីសិទ្ធិមនុស្សលាហីដែលដាក់ឈ្មោះតាមអ្នកគាំទ្រសំខាន់របស់ច្បាប់នេះគឺ សមាជិកព្រឹទ្ធសភារដ្ឋវើម៉ុន លោក ប៉ាទ្រិក លាហី គឺមានបំណងថា ការពិនិត្យលើជីវប្រវត្តិត្រូវការជាចាំបាច់សម្រាប់អ្នកទទួលការបណ្តុះបណ្តាលទាំងអស់។ ប៉ុន្តែរបាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិកបានរកឃើញថា ស្ថានទូតមិនបានរក្សាទុកកំណត់ហេតុនៃការពិនិត្យថ្នាក់មូលដ្ឋានរបស់ខ្លួន ហើយបានប្រើការណែនាំហួសសម័យ។ របាយការណ៍នោះនិយាយថា ទីភ្នាក់ងារដទៃទៀតដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលនេះ មិនបានយល់អំពីដំណើរការ និងមិនបានបញ្ជូនឈ្មោះកម្មសិក្សាការីសម្រាប់ស៊ើបអង្កេតទេ។

ក្រសួងការបរទេសសហរដ្ឋអាមេរិកបាននិយាយថា ខ្លួនមិនអាចអត្ថាធិប្បាយលើករណីបុគ្គលនីមួយៗបានទេ។ អ្នកស្រី ជូល្យេ ស្រ្តកឃី អ្នកនាំពាក្យ បានសរសេរក្នុងសារអ៊ីម៉េលថា "យើងមានកាតព្វកិច្ចរបស់យើងស្ថិតក្រោមដំណើរ



ក្មេងប្រុសជិះកង់កាត់តាមភូមិស្ពានជេសក្នុងខែឧសភា។ រូបថតដោយ Lauren Crothers

ការពិនិត្យជ្រើសរើសនៃច្បាប់សិទ្ធិមនុស្សលាហីយ៉ាងហ្មត់ចត់។ ស្របតាមច្បាប់ និងគោលនយោបាយសហរដ្ឋអាមេរិក ក្រសួងការបរទេសសហរដ្ឋអាមេរិកពិនិត្យដោយផ្ចិតផ្ចង់លើជំនួយរបស់ខ្លួនទៅឱ្យកងកម្លាំងសន្តិសុខបរទេស ក៏ដូចជាកម្មវិធីជំនួយសន្តិសុខនៃក្រសួងការពារជាតិមួយចំនួន"។

មន្ត្រីកម្ពុជាមិនពិភាក្សាអំពីកំណត់ហេតុសិទ្ធិមនុស្សនៃអ្នកដែលបណ្តុះបណ្តាលដោយសហរដ្ឋអាមេរិកទេ។ ការប៉ុនប៉ងជួបនិយាយជាមួយអ្នកនាំពាក្យក្រសួងមហាផ្ទៃនិងក្រសួងការពារជាតិមិនសម្រេចទេ។ មន្ត្រីយោធាជាន់ខ្ពស់បានបង្វែរសំណួរទៅនាយឧត្តមសេនីយ៍ មាស សុភា មេបញ្ជាការកងទ័ពជើងគោក។ តាមរយៈលេខារបស់លោក នាយឧត្តមសេនីយ៍ សុភាបដិសេធមិនធ្វើអត្ថាធិប្បាយទេ។

អ្នកស្រី ឡោក ខេង សមាជិកគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាច និងជាសមាជិកនៃគណៈកម្មការសិទ្ធិមនុស្សរដ្ឋសភាបានការពារកងកម្លាំងសន្តិសុខប្រទេសរបស់អ្នកស្រី។ អ្នកស្រីបានមានប្រសាសន៍ក្នុងបទសម្ភាសមួយថា "និយាយជារួម ខ្ញុំជឿថា រាល់មេបញ្ជាការទាំងអស់អនុវត្តភារកិច្ចរបស់ខ្លួនស្របតាមច្បាប់"។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី ជាស្ថាប័នបង្កើតគោលនយោបាយស៊ីវិល បានមានប្រសាសន៍ថា នៅប្រទេសកម្ពុជានរណាដែលត្អូញត្អែរអំពីការធ្វើបាបដោយយោធាអាចស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់។

អ្នកនាំពាក្យរូបនេះបានមានប្រសាសន៍ថា "យើងជាសមាជិកនៃអង្គការសហប្រជាជាតិ ហើយជានីតិរដ្ឋ។ យើងពិតជាមានមេធាវី។ យើងពិតជាមានប្រព័ន្ធតុលាការ។ នរណាដែលគេធ្វើបាបអាចប្តឹងទៅតុលាការ។ នោះជាក្បួនច្បាប់របស់នីតិរដ្ឋ"។

លោក បួន ណារិទ្ធ អ្នកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការលីកាដូបានបង្ហាញឈ្មោះមេបញ្ជាការមួយរូបដែលលោកនិយាយថាបានជាប់ពាក់ព័ន្ធក្នុងការបណ្តេញចេញទាំងបង្ខំ ដែលឈ្មោះនោះក្រោយមកមាននៅក្នុងទូរលេខស្ថានទូតសហរដ្ឋអាមេរិកដែលបានផ្តល់ការបញ្ជាក់ថា ស្អាតស្អំជាបឋមដើម្បីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលប្រឆាំងភេរវកម្ម និងសន្តិសុខផែសមុទ្រ។

លោក ណារិទ្ធ បាននិយាយថា វរសេនីយ៍ឯក សេង ភោគ គឺជាមេបញ្ជាការរងនៃប្រតិបត្តិការសឹករងខេត្តនៃកងយោធពលខេមរភូមិន្ទ ហើយស្ថិតក្នុងចំណោមមេបញ្ជាការដែលឈរបញ្ជា ដែលលោក ណារិទ្ធ បានឃើញចុះមកដល់ភូមិស្ពានជេសដែលត្រូវបានភ្លើងឆេះអស់ក្នុងពេលបណ្តេញចេញពីដីធ្លី។

លោក ណារិទ្ធ បាននិយាយថា "មានបីនាក់ដែលស្គាល់ឈ្មោះច្បាស់គឺ សេង ភោគ ផូ ម៉ុងសាន និងវង្ស ប៊ុនថន" ដែលពួកគេសុទ្ធតែជាមេបញ្ជាការកងរាជអាវុធហត្ថខេត្ត។ កងរាជអាវុធ ហត្ថគឺជាអង្គភាពអនុវត្តច្បាប់យោធាដែលតែងតែមានតួនាទីត្រួតគ្នានឹងនគរបាល។

រយៈពេលពីរឆ្នាំបន្ទាប់ពីការបំផ្លាញភូមិស្ពានជេស ស្ថានទូតអាមេរិកបានប្រាប់ក្រុងវ៉ាស៊ីងតោនថា ខ្លួនមិនអាចរកឃើញ "ព័ត៌មានគួរឱ្យជឿទុកចិត្ត"ដែលភ្ជាប់វរសេនីយ៍ឯក ភោគ ទៅនឹងការរំលោភសិទ្ធិមនុស្សទាំងស្រុងទេ ហើយក៏បានផ្តល់ការយល់ព្រមជាបឋមឱ្យលោកចូលរួមក្នុងវគ្គបណ្តុះបណ្តាលប្រឆាំងភេរវកម្ម។

ការសម្រេចចិត្តចុងក្រោយរបស់ក្រុងវ៉ាស៊ីងតោនក្នុងការបណ្តុះបណ្តាលវរសេនីយ៍ឯក ភោគ គឺមិនបានបញ្ចូលនៅក្នុងទូរលេខដែលបែកធ្លាយទេ។ ការប៉ុនប៉ងសុំការធ្វើអត្ថាធិប្បាយពីសំណាក់មន្ត្រីកងរាជអាវុធហត្ថមិនបានសម្រេចទេ។

ប៉ុន្តែក្នុងបណ្តាមន្ត្រីរាប់រយរាប់ពាន់នាក់នៃបុគ្គលិក និងអង្គភាពបរទេសដែលពិនិត្យរាល់ឆ្នាំដោយក្រសួងការបរទេសសហរដ្ឋអាមេរិកនោះ មានត្រឹមតែមួយភាគតូចប៉ុណ្ណោះដែលត្រូវច្រានចោលក្នុងពេលការពិនិត្យលើកទីពីរនៅក្នុងក្រុងវ៉ាស៊ីងតោន ដែលនៅទីនោះមានអ្នកពិនិត្យជ្រើសរើសមួយក្រុមដែលមានពេលតែពីរបីនាទីប៉ុណ្ណោះដើម្បីពិនិត្យករណីនីមួយៗ។

នៅពេលដែល១00Reportersចុះទៅដល់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តក្នុងខែមីនាឆ្នាំ២០១៥ មន្ត្រីនៅទីនោះបាននិយាយថា វរសេនីយ៍ ភោគ កំពុងតែធ្វើដំណើរ។ មិនអាចរកបានព័ត៌មានទាក់ទងវរសេនីយ៍ឯករូបនេះទេ។ ឧត្តមសេនីយ៍ត្រី លោក ខេង ទីតូ អ្នកនាំពាក្យកងរាជអាវុធហត្ថលើផ្ទៃប្រទេសបានមានប្រសាសន៍ថា លោកមិនបានដឹងអំពីការបណ្តេញចេញពីដីធ្លីនោះទេ ហើយមិនអាចធ្វើអត្ថាធិប្បាយបានឡើយ។ អ្នកនាំពាក្យរូបនេះបានមានប្រសាសន៍ថា "ខ្ញុំមិនដឹងអំពីករណីទាំងនេះថា វាបានកើតឡើងយ៉ាងម៉េចទេពីដំបូង"។

នៅព្រឹកនៃថ្ងៃដែលមានការបណ្តេញចេញនោះ ដំបូង អ្នកភូមិបានព្យាយាមឃាត់កម្លាំងសន្តិសុខមិនឱ្យចូលជិត។ យោងតាមអតីតអ្នកភូមិឱ្យដឹងថា ការប្រវាយប្រតប់ និងការចោលដុំថ្មបានកើតឡើង។

លោក រ៉េន បាននិយាយថា "គេបានបាញ់តម្រង់មកលើប្រជាពលរដ្ឋប្រផិតៗនឹងដី ដើម្បីបើកផ្លូវព្រោះមនុស្សច្រើនពេក"។

**តទៅលេខក្រោយ**

តមកពីទំព័រទី ១៤

## តំណាងរាស្ត្រគណបក្សប្រឆាំងត្រូវបាន...

បែបនេះអាចនឹងឈានដល់ការចាប់ខ្លួន។

ជាញឹកញាប់តំណាងរាស្ត្ររូបនេះក៏បានបង្ហោះដែរនូវអ្វីដែលលោកនិយាយថាជាផែនទីបារាំងត្រឹមត្រូវដែលបង្ហាញពីព្រំដែនភាគឦសានរបស់កម្ពុជា ជាមួយវៀតណាមដែលរដ្ឋធម្មនុញ្ញទទួលស្គាល់ គឺជាអ្វីដែលអាចគេប្រើប្រាស់បានសម្រាប់ការកំណត់ព្រំដែន។

លោក អ៊ុំ សំអាន បានសរសេរកាលពីខែកញ្ញាថា "ខ្ញុំនិយាយថា ផែនទីរបស់រដ្ឋាភិបាលខុសច្បាប់ ព្រោះផែនទីទាំងនោះខុសពីផែនទីដែលមានចែងក្នុងមាត្រា២ នៃរដ្ឋធម្មនុញ្ញ" ដោយហៅផែនទីព្រំដែនកម្ពុជា-វៀតណាមដែលលោក ហ៊ុន សែន មានថាជា "មរតកបន្សល់ទុកពីយួននៅទសវត្សរ៍ឆ្នាំ១៩៨០"។

"យួន" គឺជាពាក្យហៅសំដៅលើជនជាតិវៀតណាម ដែលមនុស្សជាច្រើនយល់ថា ជាការប្រមាថ ប៉ុន្តែត្រូវបានប្រើប្រាស់ជាញឹកញាប់ដោយគណបក្សប្រឆាំងដែលជាយូរមកហើយតែងតែព្យាយាមកេងចំណេញពីការពិតដែលវៀតណាមបានលើកបន្តុបលោក ហ៊ុន សែន និងរដ្ឋាភិបាលរបស់លោកឱ្យឡើងកាន់អំណាចអំឡុងយោធាវៀតណាមត្រួតត្រាកម្ពុជាពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩។

យោងតាមលោក ហួត សុធី ស្នងការរងខេត្តសៀមរាប បានឱ្យដឹងថា លោក អ៊ុំ សំអាន ត្រូវបានចាប់ខ្លួនកាលពីម្សិលមិញដែលធ្វើឡើង២ខែបន្ទាប់ពីរងការប្រកាន់ថាលោកប្រព្រឹត្តបទល្មើស ហើយការចាប់ខ្លួនខណៈគាត់កំពុងដកប្រាក់ពីទូអេធីអឹមនេះបង្កឱ្យមានការចោទសួរកាន់តែច្រើនអំពីអនាគតនៃអភ័យឯកសិទ្ធិដែលផ្តល់ជូនតំណាងរាស្ត្រ។

អភ័យឯកសិទ្ធិផ្តល់ឱ្យតំណាងរាស្ត្រជាប់ឆ្នោតទាំងអស់តាមមាត្រា៨០នៃរដ្ឋធម្មនុញ្ញចែងថា "ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា...វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង"។

សំឡេងភាគច្រើនពីរភាគបីក្នុងរដ្ឋសភាត្រូវការចាំបាច់ដើម្បីដកអភ័យឯកសិទ្ធិតំណាងរាស្ត្រជានីតិវិធីមួយដែលគណបក្សប្រជាជនកម្ពុជាបានទទួលប្រយោជន៍ពេញលេញក្នុងអាណត្តិកន្លងមក ដើម្បីដាក់ពន្ធនាគារតំណាងរាស្ត្រគណបក្សប្រឆាំង។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាចាប់តាំងពីការបោះឆ្នោតឆ្នាំ២០១៣មកមិនមានសំឡេងភាគច្រើនបែបនេះទេ។

លោក គល់ បញ្ញា នាយកប្រតិបត្តិនៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជាបាននិយាយថា ការបកស្រាយទូលំទូលាយនូវពាក្យ "បទល្មើសជាក់ស្តែង" ដែលត្រូវគេប្រើដើម្បីចាប់ខ្លួនលោក អ៊ុំ សំអាន ទាក់ទិនទៅនឹងការបង្ហោះតាមអ៊ីនធឺណិត៦ខែមកហើយ បានធ្វើឱ្យការការពារដែលផ្តល់ដោយមាត្រា៨០គ្មានន័យជាសំខាន់។



លោក គល់ បញ្ញា និយាយថា "រដ្ឋធម្មនុញ្ញលែងបានការហើយពេលនេះ? ពាក់ព័ន្ធការការពារតាមផ្លូវច្បាប់របស់ខ្លួនចំពោះសមាជិករដ្ឋសភាគឺមិនបានការ។ រដ្ឋាភិបាលឥឡូវនេះអាចបន្តការចាប់ខ្លួនសមាជិករដ្ឋសភាតាមដែលខ្លួនចង់"។

លោកបាននិយាយថា "រដ្ឋសភាត្រូវតែចាត់វិធានការជាបន្ទាន់និងសួររដ្ឋាភិបាលហេតុអ្វីពួកគេរំលោភរដ្ឋធម្មនុញ្ញ។ គេអាចស្នើញត្តិមួយដើម្បីសួររដ្ឋាភិបាលឱ្យពន្យល់មូលហេតុដែលពួកគេបានធ្វើដូចនេះ"។

ទោះជាយ៉ាងនេះក្តី លោក ឡេង ប៉េងឡុង អ្នកនាំពាក្យរដ្ឋសភា និងជាអគ្គលេខាធិការដ៏ចាស់បាននិយាយថាលោកបានយល់ព្រមឱ្យចាប់ខ្លួនលោកសំអានលើហេតុផលនៃចរិតគឃ្លើនយ៉ាងច្បាស់នៃការបង្ហោះតាមអ៊ីនធឺណិតរបស់គាត់។

លោក ឡេង ប៉េងឡុង បាននិយាយថា "ខ្ញុំមិនទាន់បានទទួលរបាយការណ៍ណាមួយពីសមត្ថកិច្ចនៅឡើយ ប៉ុន្តែខ្ញុំគិតថា សមត្ថកិច្ចប្រហែលមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីចាប់ខ្លួនលោក អ៊ុំ សំអាន។ ខ្ញុំគិតថា ការចាប់ខ្លួននេះមិនល្មើសច្បាប់ទេ ពីព្រោះលោក អ៊ុំ សំអាន បានប្រព្រឹត្តបទល្មើសជាក់ស្តែង"។

នេះមិនមែនជាលើកដំបូងទេដែលតំណាងរាស្ត្រមួយរូបត្រូវបានចាប់ខ្លួន? បើទោះជាមានអភ័យឯកសិទ្ធិរបស់ខ្លួនក៏ដោយ។ តាមបញ្ជារបស់លោកហ៊ុនសែនកាលពីខែសីហាសមាជិកព្រឹទ្ធសភាគណបក្សប្រឆាំងគឺលោក ហុង សុខហួរ ត្រូវបានគេចាប់ដាក់ពន្ធនាគារពីបទក្លែងឯកសារនិងញុះញង់ទាក់ទិននឹងសន្ធិសញ្ញាព្រំដែនក្លែងក្លាយជាមួយប្រទេសវៀតណាម ដែលគាត់ប្រើក្នុងបទបង្ហាញដែលបានបង្ហោះតាមហ្វេសប៊ុក។

នៅពេលដែលគណបក្សប្រជាជនកម្ពុជាមានសំឡេងពីរភាគបីចាំបាច់ក្នុងព្រឹទ្ធសភា ដើម្បីដកអភ័យឯកសិទ្ធិរបស់លោក ហុង សុខហួរ សមាជិកព្រឹទ្ធសភារបស់គណបក្សកាន់អំណាចនេះបានជួបប្រជុំ ហើយបានសម្រេចមិនដកអភ័យឯកសិទ្ធិគាត់ទេដោយលើកឡើងនូវវីដេអូដែលគេលុបចោលនៅពេលនោះថាជាករណីនៃ "បទល្មើសជាក់ស្តែង" ដែលអនុញ្ញាតឱ្យដាក់ពន្ធនាគាររូបគាត់ដដែល។

កាលពីម្សិលមិញ ភាពស្រដៀងគ្នារវាងករណីទាំងពីរគឺច្បាស់លាស់ដដែលចំពោះលោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃដែលបានលើកឡើងដើមចមនៃការចាប់ខ្លួនលោក ហុង សុខហួរ ក្នុងការការពារការចាប់ខ្លួនលោក អ៊ុំ សំអាន។

លោកនិយាយថា "ករណីលោក អ៊ុំ សំអាន មិនខុសគ្នាពីករណីលោក ហុង សុខហួរ ទេ ពីព្រោះគាត់បានរិះគន់រដ្ឋាភិបាលអំពីការលក់ដីឱ្យវៀតណាម ហើយគាត់ក៏បានរិះគន់រដ្ឋាភិបាលថា បានប្រើផែនទីក្លែងក្លាយដែរ"។

នៅពេលដែលក្រុមមន្ត្រីបានទទួលយកការបកស្រាយទូលំទូលាយនៃពាក្យ "បទល្មើសជាក់ស្តែង" លោក ហ៊ុន សែន បានបញ្ចេញទស្សនៈតិចតួចអំពីអភ័យឯកសិទ្ធិសភា ដោយលោកបានព្រមានថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិប្រាំពីររូបផ្សេងទៀតដែលជាប់ចោទពីបទ "ដឹកនាំកុបកម្ម" មុនពេលទទួលអាសនៈរបស់ខ្លួននៅខែសីហាឆ្នាំ២០១៤អាចជាប់ពន្ធនាគារ។

លោក ហ៊ុន សែន បាននិយាយក្នុងសុន្ទរកថានៅខែមករាឆ្នាំ២០១៥ថា "តំណាងរាស្ត្រប្រាំពីររូបនោះនឹងនៅតែជាប់ពន្ធនាគារ ព្រោះអ្នកឯងបានទទួលអភ័យឯកសិទ្ធិបន្ទាប់ពីអ្នកឯងត្រូវរងការចោទប្រកាន់"។ សូមសិក្សាច្បាប់មើលទៅ។ ខាងអ្នកឯងចេះច្បាប់ ហើយខាងយើងក៏ចេះច្បាប់ដែរ"។

លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងដែលលោកខ្លួនឯងឥឡូវនេះកំពុងរស់នៅនិរទេសដោយខ្លួនឯងនៅប្រទេសបារាំង ដើម្បីគេចចេញពីការចោទប្រកាន់ និងទោសកាន់តែច្រើនឡើងមិនធ្លាប់មានពីមុនមក? បាននិយាយកាលពីម្សិលមិញថា ការចាប់ខ្លួនលោក អ៊ុំ សំអាន គឺជាសញ្ញាអាក្រក់មួយចំពោះការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតជាតិឆ្នាំ ២០១៨ដែលជិតមកដល់។

លោក សម រង្ស៊ី បានសរសេរក្នុងអ៊ីម៉េលមួយពីទីក្រុងប៉ារីសថា "ការចាប់ខ្លួននេះឱ្យប្រផ្នូលអាក្រក់ចំពោះបរិយាកាសជុំវិញការបោះឆ្នោតដែលជិតមកដល់។ វាជាការព្រមានដល់អ្នកដែលទន្ទឹងរង់ចាំការបោះឆ្នោតដែលអាចទទួលយកបាននៅឆ្នាំ២០១៧និង២០១៨? ក្នុងនោះមានសហគមន៍អន្តរជាតិផង"។ **សុខុម និង និត**




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វើកឃឺខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com

សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# កម្រងរូបភាព TAE KWON DO




Dreacut Team































*The 15th Annual KTA Tournament*
*April 9, 2016*
*Woburn Boys & Girls Club*







# ស្ទឹងខ្ពបត្របែកទាក់ទាញ ភ្ញៀវទេសចរកាន់តែច្រើនឡើង



**ខេត្តកំពត** : ស្ទឹងខ្ពបត្របែកកើតចេញពីប្រជាជនជាអ្នកជីកក្រោមការបង្ខិតបង្ខំពីពួកឃាតករប៉ុលពតក្នុងយុគខ្មៅងងឹតនាឆ្នាំចិតសិបប្រាំ។ ទន្ទឹមនឹងនោះមនុស្សជាច្រើនត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃតែទោះបីយ៉ាងណាបច្ចុប្បន្ននេះស្ទឹងឈាមនេះ បានប្រែក្លាយពីភាពអប្បលក្ខណ៍ទៅជាទីឋានមួយស្រស់បំព្រងមានធម្មជាតិព្រៃភ្នំ និងផ្ទៃទឹកល្អល្អេវជាទីមនោរម្យមិនដូចពីកាលជាងសាមសិបឆ្នាំមុននោះឡើយ។ មិនត្រឹមប៉ុណ្ណោះ ស្ទឹងនេះបានក្លាយទៅជារមណីយដ្ឋានមួយដ៏ប្រណីត ហើយទាក់ទាញភ្ញៀវទេសចរជិតឆ្ងាយមកទស្សនាកម្សាន្តកាន់តែច្រើនឡើងៗជាងពេលមុនៗ ទាំងអស់។ ស្ទឹងខ្ពបត្របែកមានវិសាលភាពធំធេងមួយផ្នែកស្ថិតនៅក្នុងទឹកដីកំពតមួយផ្នែកទៀតស្ថិតក្នុងដីតាកែវ ហើយតែងទទួលទឹកពីស្ទឹងភេ រួចបន្តចែកចាយហូរចាក់ទៅកាន់ស្ទឹងស្លាគូ ប្រឡាយគ្មោតជុំនិងមួយ ចំណែកស្រោចស្រពផ្ទៃដីកសិកម្ម។ រដូវវស្សាទឹកឡើងពេញប្រៀប ហើយរដូវប្រាំងវិញពាក់កណ្តាលប៉ែកខាងកើតត្រូវបានក្លាយទៅជាដីគោកនៅសល់តែប៉ែកខាងលិចប៉ុណ្ណោះ។ តែទោះបីយ៉ាងណានៅតាមសងខាងក្បែរមាត់ ច្រាំងគេអាចធ្វើស្រែចម្ការបានដោយទទួលទិន្នផលខ្ពស់ហើយមិនត្រឹមតែបម្រើអោយវិស័យទេសចរមួយមុខនោះទេ គឺកសិកម្មផងដែរ។ សព្វថ្ងៃយើងកំពុងតែស្រូបទាញផលប្រយោជន៍ជាច្រើនផ្នែកពីស្ទឹងនេះ តែយើងគួរដឹងថាទម្រាំតែកើតបានទៅជាស្ទឹងនេះមួយមានមនុស្សស្លូតត្រង់ជាច្រើននាក់ត្រូវបានសម្លាប់។ បច្ចុប្បន្ននេះទីកន្លែងដែលភ្ញៀវទេសចរចាប់អារម្មណ៍ និងនាំគ្នាមកលេងច្រើនជាងគេមានតែត្រង់ចំណុចស្ពានថ្មមួយនៅជាប់នឹងភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ។ ប្រហែលដប់ឆ្នាំហើយ ដែលស្ទឹងខ្ពបត្របែកស្ថិតក្នុងក្រសែភ្នែកអ្នកទស្សនាតែមានតិចគ្នាណាស់មកកាន់ទីនោះ។ ចាប់តាំងពីឆ្នាំ ២០១៣មក គេសង្កេតឃើញមានកំណើនភ្ញៀវទេសចរមកកម្សាន្តកាន់តែច្រើនឡើងជាងឆ្នាំមុនៗជាលំដាប់។ ព្រោះតែឥឡូវនេះដោយសារ ស្ទឹងខ្ពបត្របែក មានបន្ថែមពោះវៀនឡាន និងអូប័រសម្រាប់ជូលជិះហែលលេងរឹតតែធ្វើឱ្យការកម្សាន្តមានភាពកាន់តែសប្បាយជាងមុន។ សបញ្ជាក់ថាពីមួយឆ្នាំទៅមួយឆ្នាំស្ទឹងខ្ពបត្របែកកាន់តែមានការជឿនលឿនដើម្បីទាក់ទាញអ្នកទស្សនាអោយចូលចិត្តមកលេងកម្សាន្ត។ ទៀងពេលមិនថាថ្ងៃសៅរ៍ អាទិត្យ ឬថ្ងៃបុណ្យទានប្រពៃណីនានានោះទេ តែងមានភ្ញៀវទេសចរប្រុសស្រីជិតឆ្ងាយមកកម្សាន្តមិនដែលដាច់។ ភាគច្រើនសុទ្ធតែជាយុវជនយុវនារីក្មេងៗតែងបណ្តើរគ្នាជាគូៗ ក្នុងនាមជាប្តីប្រពន្ធជាសង្សារ ឬជាមិត្តភក្តិប្រកៀកប្រកើយគ្នាខ្លះដើរខ្លះឈរលើស្ពានខ្លះទៀតឈរនៅតាមមាត់ស្ទឹង។ កែវភ្នែកទាំងគូរបស់ពួកគេសម្លឹងតយគន់មើលវាលផ្ទៃទឹករលករលេញធំល្ហល្ហេវ និងជងភ្នំវែងអន្លាយប្រកបដោយធម្មជាតិខៀវស្រងាត់ដែលស្ថិតនៅត្រើយម្ខាងទៀតយ៉ាងជក់ចិត្តជិតអារម្មណ៍។ ទិដ្ឋភាពទាំងនោះ មានភាពរស់រវើករវាំទៅមកតាមចង្វាក់នៃព្រះពាយ ហើយត្រូវបន្ថែមពណ៌ជូនស្រទំ ជូនមានពន្លឺទៅតាមបរិយាកាស។ ព្រៃភ្នំរុក្ខជាតិ និងផ្ទៃទឹកស្ទឹងខ្ពបត្របែកប្រៀបបាននឹងផ្ទាំងគំនូរមួយដែលគូសវាសដោយទឹកថ្នាំរបស់វិចិត្រករដែងកណាម្នាក់អញ្ចឹង ហើយកំពុងផុសអណ្តែតឡើងលើទំព័រពិភពលោកគ្មានថ្ងៃរលុបបាត់នោះឡើយ។ ទន្ទឹមនឹងនោះសូរសន្ទឹកទឹកហូរក្រោមស្ពានឈ្មួរៗហាក់មិនចេះហត់នឿយហើយបង្កើតបានជាតន្ត្រីមួយវង់កំពុងប្រគំរាយទំនុករាប់ពាន់បទបំពេបំពេញអារម្មណ៍ និងបេះដូងអ្នកទេសចរគ្រប់គ្នាផងដែរ។ នៅក្នុងផ្ទៃទឹកវិញពួកគេកំពុងសប្បាយនឹងការបណ្តែតខ្លួនក្នុងពោះវៀនឡាន ហើយកញ្ជ្រោកបោកបាចសាចដាក់គ្នាប្រកបដោយមនោសញ្ចេតនាសប្បាយរីករាយ។ អូប័រវិញក៏បានបោះពួយសន្ទុះលឿនស្ទេវដែលបត់បែនទៅមកលើទឹកពាសពេញផ្ទៃស្ទឹងដើម្បីនាំអ្នកទេសចរទាំងឡាយទៅកាន់ទីឆ្ងាយៗកម្សាន្តលេងយ៉ាងរំភើបព្រឺព្រួច។ នៅតាមមាត់ស្ទឹងនាពេលល្ងាចវិញក្រោយពីជិះពោះវៀនឡាន និងអូប័រ ចប់ពួកគេក៏បានជួបជុំគ្នាញ៉ាំនំចំណីអាហារ និងភេសជ្ជៈយ៉ាងឆ្ងាញ់ពិសា ក្រោមខ្យល់ត្រជាក់បក់មករំភើយៗពិតជារ៉ូមែនទិកខ្លាំងណាស់។ ចំពោះអ្នកដែលបានមកកម្សាន្ត



តទៅទំព័រទី២១



# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

## ត្រួតពិនិត្យទ្រព្យសម្បត្តិរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

មុនព្រះពុទ្ធសំដែងធម៌ទេសនាប្រោសសត្វ ព្រះអង្គបានត្រាស់ដឹងមានព្រះទ័យបរិសុទ្ធមានករុណាគ្មានព្រំដែនឥតលំអៀង។ លោក**ឱមយ៉ិនទៀង** ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ក៏ត្រូវសំអាតខ្លួនដោយប្រកាសទ្រព្យសម្បត្តិ មានផ្ទះប៉ុន្មាន មានមានប្រាក់ប៉ុន្មានដុល្លារ មានប្រពន្ធចុងដូចពាក្យគេថាទេ? នៅប្រទេសកម្ពុជាអំពើពុករលួយស៊ីរូងដល់ក្អួង បានបាត់ថវិកាជាតិក្នុង១ឆ្នាំៗរាប់រយលានដុល្លារ។ លោកប្រធានកំចាត់បានខ្លះតែអ្នកតូចតាច ប៉ុន្តែអ្នកមានអំណាចនិងឧកញ៉ាគ្រាក់ៗជាបក្សពួករបស់លោកប្រធាន ដែលមានប្រាក់រាប់រយរាប់ពាន់លានដុល្លារ លោកប្រធានមិនបានកំចាត់ឡើយ។ ចំណែក ស្រីកំណាន់ចិត្តមានស្ទើរគ្រប់អ្នកមានអំណាចបុណ្យស័ក្តិនិងអ្នកមានអំណាចដុល្លារ ដែលបានមកពីការកាប់បំផ្លាញព្រៃឈើ ពីប្លន់ដីរបស់ប្រជាពលរដ្ឋ។ មានអ្នកមានអំណាចខ្លះរំលោភលើស្ត្រីហើយសម្លាប់គេចោលទៀតដើម្បីបំបិទភ័ស្តុតាង ស្ត្រីខ្លះត្រូវរងគ្រោះដោយទឹកអាស៊ីដដោយសារប្រពន្ធដើម។

សកម្មភាពរបស់លោក **ឱមយ៉ិនទៀង** ពេលនេះ បានយកចិត្តទុកដាក់ណាស់ចំពោះបញ្ហាលោក**កឹមសុខា** ហើយស៊ីសង្វាក់គ្នាផង ទំនងដឹងគ្នាជាមុន ដោយមើលឃើញថា ការដាក់កំហុសលើលោកកឹមសុខាអំពីរឿងស្រីញីហាក់ដូចជាគ្មានទម្ងន់អ្វីសោះ ជារឿងធម្មតាទោះបីរឿងពិត ហើយជារឿងលួចថតរំលោភសិទ្ធិបុគ្គលទៀតផង សូម្បីតុលាការក៏ច្រានចោលពុំទទួលពាក្យ គ្រាន់តែប្រើពាក្យជំនួសថា សូមឲ្យការិយាល័យប្រឆាំងភេរវកម្មពិនិត្យអង្កេតចុះ បើពិតដូចន័យនេះមែន សូមសរសើរសមាជិកតុលាការខ្មែរមានពន្លឺយុត្តិធម៌ខ្លះហើយ ដោយឧត្តមគតិដ៏ខ្ពស់របស់តុលាការ ដូច្នេះត្រូវរកលេសចោទថាពុករលួយវិញ ចោទពុករលួយក៏ពិបាកទៀត ព្រោះលោកកឹមសុខាមិនធ្វើជាអ្នករដ្ឋការនាំឲ្យពុករលួយ បានប្រាក់ខែពីធ្វើតំណាងរាស្ត្រនិងបានពីមុខរបរបន្តិចបន្តួច។ ដូច្នេះ លោក**ឱមយ៉ិនទៀង** ត្រូវបញ្ឈប់អំពើបៀតបៀន ប្រយ័ត្នបាចអង្កាមប្រាស់ខ្យល់ ចំណែក សកម្មជនគណបក្សសង្គ្រោះជាតិមានភាពស្ងប់ស្ងៀមទំនងជាដឹងថា នេះជាឆាកមួយដែលគេបង្កើតឡើងដើម្បីកំចាត់អ្នកដឹកនាំគណបក្សគេ៕

វត្តខ្មែរកាណាដា.ថ្ងៃ២៤មីនា២០១៦:www.hoksavann.org:savannhok@yahoo.com

# ប្រសិទ្ធភាពក្នុងការការពារថ្លើមប្រឆាំងមហារីករបស់គ្រាប់ល្ហុង

មនុស្សទូទៅពេលបរិភោគល្ហុងតែងចោលគ្រាប់របស់វា ។ ពុំមានមនុស្សច្រើនទេដែលបានដឹងថា គ្រាប់ល្ហុងជាអាហារជំនួយប្រឆាំងមហារីក និងការពារថ្លើមរបស់អ្នកបានយ៉ាងប្រសើរបំផុត ។

-ប្រសិទ្ធភាពនៃគ្រាប់ល្ហុងគ្រាប់ល្ហុងសម្បូរទៅដោយ axit oleic និង axit palmitic ។ សារធាតុទាំង២នេះ សុទ្ធតែមានប្រសិទ្ធភាពប្រឆាំងនឹងមហារីកពិតជាល្អប្រសើរសំរាប់សរីរាង្គ ។ ក្នុងវេជ្ជសាស្ត្របូរាណចិន និងជប៉ុន ចាត់ទុកថាគ្រាប់ល្ហុងមានសមត្ថភាពរំសាយជាតិពុល និងបង្កើនសមត្ថភាពរបស់ថ្លើម ។ បទពិសោធន៍ប្រពៃណីតៗគ្នាតែងជឿថា គ្រាប់ល្ហុងមានសារធាតុបង្ការមេរោគចម្លង និងការពារមុខងាររបស់ក្រលៀន ។ ការសិក្សាមួយនៅនីហ្សេរីយ៉ាឱ្យដឹងថា ដោយការបរិភោគគ្រាប់ល្ហុង ក្មេងៗ ៧៦.៧ % បានចៀសផុតពីពួកប៉ារ៉ាស៊ីតក្នុងពោះវៀន ។

-គប្បីបរិភោគគ្រាប់ល្ហុងបែបណា? គ្រាប់ល្ហុងតូចៗមានជាតិល្វីងតិចជាងគ្រាប់ធំៗ ។ ពេលចាប់ផ្តើមរៀនបរិភោគគប្បីជ្រើសយកគ្រាប់តូចៗ បន្ទាប់មកយកគ្រាប់ធំឡើងៗ ។ បញ្ហាស្ថិតត្រង់គ្រាប់តូចៗងាយលេបជាង ។ អ្នកអាចបរិភោគទាំងសាច់ និងគ្រាប់ល្ហុង១សប្តាហ៍២លើក ។ ពុំគួរបរិភោគច្រើនដែលធ្វើឱ្យប្រព័ន្ធរំលាយអាហារពិបាកទ្រាំទ្រ និងបាត់ការឃ្លានចំណី ៕



## តមកពីទំព័រទី ១៣ ការស៊ើបអង្កេតធ្វើឡើងលើការអះអាង...

"នៅថ្ងៃដែលខ្ញុំមកដល់ ខ្ញុំថែមទាំងមិនដឹងផង ទើបតែខ្ញុំបានឃើញនៅតាមប្រព័ន្ធបណ្តាញសង្គមនៅថ្ងៃបន្ទាប់មកពីប្រទេសកម្ពុជា គឺគេនិយាយថា គេកំពុងប្តឹងអ្នកឯងពីនេះ ពីនោះ"។

ឧត្តមសេនីយ៍ឯក ម៉ាណែត បានមានប្រសាសន៍បន្ថែមថា "ទោះជាយ៉ាងណាគាត់ជំពប់ជើង ដួលហើយសូម្បីតែប៉ូលិសក៏នៅទីនោះដែរ មានមន្ត្រីប៉ូលិសពីរនាក់នៅទីនោះ។ ប្រសិនបើវាជាការវាយដំ ខ្ញុំគិតថា ឱ្យអង្គរក្សនឹងត្រូវចាប់ខ្លួនហើយ"។

រឿងរ៉ាវរៀបរាប់របស់ឧត្តមសេនីយ៍ឯក ម៉ាណែត បង្ហាញឱ្យឃើញនូវការរៀបរាប់កាលពីសប្តាហ៍មុន ដោយអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី ផៃ ស៊ីផាន ដែលបានស្មានថា លោក ហេ អាចដួល ហើយបានមានប្រសាសន៍ថា លោកគ្រាន់តែបាញ់ត្រូវទឹកម្រេចដោយអង្គរក្សម្នាក់ បន្ទាប់ពីព្យាយាមវាយឧត្តមសេនីយ៍ឯក ម៉ាណែត។

លោក ហេ បាននិយាយថា ការអះអាងរបស់លោក ស៊ីផាន និងឧត្តមសេនីយ៍ឯក ម៉ាណែត គឺ គួរឱ្យអស់សំណើចណាស់ ហើយថា អ្នកតវ៉ានៅទីនោះនឹងធ្វើឱ្យនគរបាលលំបាកក្នុងការមើលឃើញនូវអ្វីដែលបានកើតឡើង។

លោក ហេ បានមានប្រសាសន៍ថា "ខ្ញុំពិតជាមិនបានជំពប់ជើងដួលទេ ហើយជាពិសេសមិនដួលផ្ងារក្រោយអ៊ីចឹងទេ។ ទីពីរ បាទ មានប៉ូលិសនៅទីនោះ ប៉ុន្តែនៅកន្លែងកើតហេតុជាក់ស្តែងមានហ្វូងមនុស្សដោយមានមនុស្សរាប់សិបនាក់ឈរនៅពាសពេញ"។

លោកបាននិយាយបន្ថែមថា "មានភាពវង្វេងវង្វាន់។ តើម៉ាណែតរំពឹងគិតថា ប៉ូលិសគឺជាអ្នកមានប្រាជ្ញាញាណ ហើយពួកគេនឹងទាញគេចេញពីហ្វូងមនុស្សក្នុងពេលកំពុងមានចលាចលឬ? ខ្ញុំចង់បានករណីហ្នឹងអីចឹងដែរ។ អ្វីដែលគាត់កំពុងនិយាយ គឺគ្មានន័យទាល់តែសោះ"។

លោក ហេ បានប៉ុនប៉ងប្រគល់ជូនឧត្តមសេនីយ៍ឯក ម៉ាណែត នូវដីកាទាក់ទងនឹងបណ្តឹងចាប់ដាក់ពន្ធនាគារដោយខុសច្បាប់ដែលដាក់ប្តឹងនៅក្នុងតុលាការសហព័ន្ធសហរដ្ឋអាមេរិកដោយមន្ត្រីគណបក្សសង្គ្រោះជាតិ គឹមាជ សុវណ្ណារ៉ា ជាពលរដ្ឋអាមេរិកាំង ដែលលោកកំពុងតែអនុវត្តទោសជាប់ពន្ធនាគាររយៈពេល២០ឆ្នាំក្នុងក្រុងភ្នំពេញ។

លោក សុវណ្ណារ៉ា ដែលមានគ្រួសាររបស់លោករស់នៅក្នុងក្រុងឡុងប៊ិច គឺត្រូវបានតុលាការរកឃើញថា មានទោសកាលពីឆ្នាំមុនពីបទដឹកនាំកុបកម្ម ដោយសារតែលោកមានវត្តមាននៅឯការតវ៉ាក្នុងក្រុងភ្នំពេញ ដែលបានក្លាយទៅជាការប្រវាយប្រតបគ្នាតាមដងផ្លូវ។ លោកគឺកំពុងតែប្តឹងឧត្តមសេនីយ៍ឯក ម៉ាណែត និងរដ្ឋាភិបាលកម្ពុជាពីបទធ្វើឱ្យខូចខាតដែលបណ្តាលមកពីការចាប់ដាក់ពន្ធនាគារដែលមេធាវីរបស់លោកនិយាយថាជាការចាប់ដាក់គុកតាមតែអំពើចិត្ត៕

## តមកពីទំព័រទី ២០ ស្ទឹងខ្លបត្របែកទាក់ទាញភ្ញៀវ...

នៅទីនេះវិញពិតជាទទួលនូវអារម្មណ៍សប្បាយ ហើយប្រកបដោយសេចក្តីសុខមិនអាចបំភ្លេចបាន ទោះបីច្រើនថ្ងៃខែកន្លងទៅមុខក៏ដោយ។ ជាពិសេសស្នាមអនុស្សាវរីយ៍ទាំងឡាយបានដក់ជាប់ក្នុងក្រអៅបេះដូងពួកគេជានិច្ច និងតែងប្រាថ្នាមកលេងឋានសួគ៌ស្ទឹងខ្លបត្របែកនេះគ្រប់នាទីដោយមិនចេះធុញទ្រាន់ឡើយ។ ផែនទីភូមិសាស្ត្រស្ទឹងខ្លបត្របែកប៉ែកខាងត្បូងជាប់នឹងដីស្រែ និងដីចម្ការរាប់ហិកតាដែលនៅក្បែរជើងភ្នំដំរីវែងអន្លាយ ចំណែកប៉ែកខាងកើតខាងជើង និងខាងលិចវិញ ជាភូមិស្រុករបស់ប្រជាជន។ ផ្លូវទៅកាន់តំបន់នោះមិនពិបាកធ្វើដំណើរដូចកាលមុននោះឡើយ ហើយប្រកបដោយសុវត្ថិភាព ទោះបីសម័យរដ្ឋកម្ពុជាកាន់កាប់ដោយពួកខ្មែរក្រហមក៏ដោយ។ បើចង់ទៅកាន់ទីនោះលុះមកដល់ទីប្រជុំជនផ្សារអង្គតាសោមហើយ យើងត្រូវបត់ទៅលិចតាមផ្លូវក្រាលកៅស៊ូមួយខ្សែប្រហែល១៧គីឡូម៉ែត្រប៉ុណ្ណោះ។ ចំពោះប្រជាជនដែលរស់នៅជិតៗនោះបានអោយដឹងថា ស្ទឹងខ្លបត្របែកមានអ្នកទេសចរមកកម្សាន្តច្រើនជាងគេនៅខែបុណ្យភ្ជុំ បុណ្យចូលឆ្នាំចិន និងបុណ្យចូលឆ្នាំខ្មែរ ព្រោះពេលនេះ ជាពេលវេលាមួយដែលពួកប្រជាជនយើងដែលចេញទៅរកស៊ីធ្វើការនៅតំបន់ឆ្ងាយៗ ត្រូវបានឈប់សម្រាកហើយវិលមកលេងស្រុកកំណើតរៀងៗខ្លួន ដើម្បីជួបជុំម៉ែឪបងប្អូន និងមិត្តភក្តិ។ ក្រោយពេលយកនំចំណី និងចង្ហាន់លុយកាក់ទៅជូនអ្នកមានគុណមានឪពុកម្តាយជាដើម និងប្រគេនព្រះសង្ឃធ្វើបុណ្យទាននៅឯវត្តរួចមកពួកគេតែងមកជួបជុំគ្នាកម្សាន្តនៅស្ទឹងខ្លបត្របែកនេះ ដើម្បីបំបាត់ការហត់នឿយភាពតប់ប្រមល់ក្នុងអារម្មណ៍បានមួយគ្រាៗមុននឹងត្រឡប់ទៅបំពេញការងាររកស៊ីរៀងៗខ្លួនវិញ។ លុះឆ្នាំក្រោយៗមកទៀតពួកគេក៏ត្រឡប់មកលេងកម្សាន្តនៅទីនេះវិញ ក្នុងពេលមានកម្មវិធីបុណ្យប្រពៃណីខ្មែរដូចជាបុណ្យភ្ជុំបិណ្ឌជាដើម។ មួយទៀតលុះត្រាតែទឹកនៅទីនេះ ស្រកចុះទើបពួកអាជ្ញាធរបើកឱ្យមកលេង បើទឹកឡើងវិញត្រូវបិទ ព្រោះខ្លាចមានគ្រោះថ្នាក់ដល់ភ្ញៀវទេសចរដែលចុះងូត ៕

# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជាឱសថស្ថានមួយដែលអាចផ្តល់ភាពជឿជាក់ដល់គ្រួសារលោកអ្នក



យើងខ្ញុំសូមជូនពរមហាប្រសើរដល់លោកអ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ារ, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្ញើថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។

ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

**លេខទូរស័ព្ទ 978-455-6554**

**លេខហ្វាក់ 978-455-9476**

## 937 Gorham St Lowell, MA, 01852

តមកពីទំព័រទី ១៩

## ការដាក់ពន្ធនាគារតំណាងរាស្ត្របក្ស...

បើលោក អ៊ុំ សំអាន សម្លាប់មនុស្សម្នាក់ ហើយរត់គេចខ្លួន ប៉ុន្តែក្រោយមកត្រឡប់មកវិញនគរបាលអាចចាប់ខ្លួនគាត់បានដោយសារតែគាត់បានប្រព្រឹត្តបទល្មើសជាក់ស្តែង ហើយគេគ្រប់គ្នាដឹងថា គាត់បានធ្វើវាពីមុន"។

ប៉ុន្តែការបកស្រាយដ៏ទូលំទូលាយអំពីវាក្យខណ្ឌស្តីពីបទល្មើសជាក់ស្តែងនេះ មិនដែលត្រូវបានលើកឡើងទេពីមុនមកអស់រយៈពេល២០ឆ្នាំមកហើយ ព្រោះគណបក្សប្រជាជនកម្ពុជាអាចទទួលបានសំឡេង២ភាគ៣នៅក្នុងការបោះឆ្នោតដើម្បីចាប់សមាជិកសភាគណបក្សប្រឆាំងដាក់ពន្ធនាគារ ហើយខ្លឹមសាររបស់វាមានមនុស្សជាច្រើនមិនឯកភាពទទួលយក។

លោក សុន ឆ័យ សមាជិកសភាគណបក្សប្រឆាំងដែលបានការពារលោក អ៊ុំ សំអាន អំឡុងសន្និសីទកាសែតមួយកាលពីសប្តាហ៍មុនបានជំទាស់ថា វាក្យខណ្ឌនោះមិនមែនមានន័យថា ជាការផ្តល់ឱកាសឱ្យមានការគេចពីច្បាប់នោះទេ ដោយអនុញ្ញាតឱ្យមានការចាប់ខ្លួនសមាជិកសភាពេលអាជ្ញាធរអះអាងថា មានភ័ស្តុតាងច្បាស់លាស់នៃការប្រព្រឹត្តបទល្មើស។

ផ្ទុយទៅវិញ លោក សុន ឆ័យ លើកឡើងថា វាក្យខណ្ឌនោះគឺមានបំណងបើកឱកាសឱ្យមានលទ្ធភាពចាប់ខ្លួនសមាជិកសភា នៅពេលមានការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដូចជាអំពើមនុស្សឃាតជាដើមដោយអនុញ្ញាតឱ្យនគរបាលធ្វើអន្តរាគមន៍ដោយពុំចាំបាច់រង់ចាំសភាបោះឆ្នោតនោះទេ។

ប៉ុន្តែទោះបីជានៅក្នុងករណីប្រព្រឹត្តបទល្មើស "ជាក់ស្តែង" ក៏ដោយតែលោក សុន ឆ័យ បានគូសបញ្ជាក់កាលពីម្សិលមិញថា ការលើកលែងនេះ គឺគ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះ ហើយមិនអនុញ្ញាតឱ្យបន្តដំណើរការផ្តន្ទាទោសឡើយ ដូចជានៅក្នុងករណីលោក អ៊ុំ សំអាន ជាដើម។

លោក សុន ឆ័យ បានមានប្រសាសន៍ថា "បន្ទាប់ពីពួកគេបានឃាត់ខ្លួនគាត់ ពួកគេត្រូវតែមានការអនុញ្ញាតពីសភាដើម្បីដកអភ័យឯកសិទ្ធិរបស់គាត់ ដើម្បីបន្តដំណើរការផ្តន្ទាទោសនៅក្នុងករណីនេះ។ រដ្ឋធម្មនុញ្ញចែងថា ប្រសិនបើចង់បន្តត្រូវតែដកអភ័យឯកសិទ្ធិ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាមិនមានសំឡេងភាគច្រើនទេ"។

បដិញ្ញាដែលតម្រូវឱ្យមានការអនុម័តដោយសំឡេងឆ្នោត២ភាគ៣នៃរដ្ឋសភា ក៏មានចែងដែរនៅក្នុងមាត្រា៨០នៃរដ្ឋធម្មនុញ្ញ។

មាត្រានេះចែងថា "ការចោទប្រកាន់ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភាវៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បីអនុម័តតាមមតិភាគច្រើន២ភាគ៣ នៃសមាជិករដ្ឋសភាទាំងមូល។ ក្នុងករណីទាំងអស់ខាងលើការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាកប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើន៣ភាគ៤នៃចំនួនសមាជិករដ្ឋសភាទាំងមូល"។

លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌បានមានប្រសាសន៍កាលពីម្សិលមិញថា វាក្យខណ្ឌចុងក្រោយនៃមាត្រានេះចែងអំពីមូលដ្ឋាននៃការបោះឆ្នោតរបស់រដ្ឋសភាកាលពីសប្តាហ៍មុនដែលអនុញ្ញាតឱ្យបន្តចោទប្រកាន់លោក អ៊ុំ សំអាន ថ្វីបើលោកមានអភ័យឯកសិទ្ធិនៅឡើយក្តី។

លោកបដិសេធថា ការគ្មានសំឡេងភាគច្រើន២ភាគ៣ ដើម្បីអនុម័តការឃុំខ្លួនលោក អ៊ុំ សំអាន មិនបានរារាំងចំណាត់ការបែបនេះសម្រាប់ករណី "បទល្មើសជាក់ស្តែង" នោះទេ ដោយលោកបកស្រាយថា មកពីលោក អ៊ុំ សំអាន មិនទទួលបានសំឡេងឆ្នោតចាំបាច់ដើម្បីផ្អាកការចោទប្រកាន់លោក។

